# ខ្មែរប៉ុស្តិ៍ ឆ្នេរខាងកើត

EAST COAST BIWEEKLY PUBLICATION

KhmerPost.us
Printing the Cambodian world news!
PHILADELPHIA
NEW JERSEY
LOWELL
VOL. 04 ISSUE 66 AUG. 27th–SEPT 9th, 2010



P.O. Box 24357, Philadelphia, PA 19120. Advertising: 267.253.3947 Fax: 215.722.2226. KhmerPostUSA@gmail.com
P.O. Box 1318, Lowell, MA 01853. Advertising: 978.758.8547. Email: KhmerPostLowell@gmail.com


មាតិការរឿង ទំព័រ


១- ក្រុមហ៊ុនប្រេង ឧស្ម័ន និងរ៉ែ.....................០៣
២- កម្ពុជា និងវិបត្តិដុល្លារភាវូបនិយកម្ម.............០៤
៣- Cambodia Daily និងប្រវត្តិព្រះអាចារ្យ.....០៤-១៣
៤- ក្តីស្នេហ៍គ្មានទីបញ្ចប់ (ត).......................១៥
៥- នាទីប្រវត្តិសាស្ត្រ និងនាទីព្រះពុទ្ធសាសនា....១៦
៦- ទឹកភ្នែគពេង (ត).............................១៧


## នៅឡូវែល : បុណ្យអុំទូកនៃសហគមន៍អាស៊ីអគ្នេយ៍

**ឡូវែល :** មនុស្សមិនតិចជាង ១ម៉ឺននាក់ទេ បានមកចូលរួមពិធីអុំទូកប្រចាំឆ្នាំរបស់សហគមន៍អាស៊ីអគ្នេយ៍ ដែលបានមករស់នៅតាំងទីនៅតំបន់ខាងជើងភាគខាងកើតនៃសហរដ្ឋអាមេរិក ។ គឺជាឱកាសមួយជួបជុំបងប្អូន មិត្តភ័ក្រដ៏ធំបង្គួរមួយដែល ខ្មែរ លាវ ថៃ បានបង្កើតឡើងបាននៅសហរដ្ឋអាមេរិកនេះ ដោយដំបូងឡើយ ក្រុមសហគមន៍ខ្មែរជាអ្នកផ្តួចផ្តើមមុនគេ ។ មកដល់ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១០ បុណ្យអុំទូកនៅឡូវែល មានអាយុ១៤ឆ្នាំ ហើយ ។

តាមការពិតថ្ងៃនៃពិធីបុណ្យដ៏អធិកអធមនេះ មិនត្រឹមតែជាការជួបជុំនៃសហគមន៍តែប៉ុណ្ណោះទេ គេដើរប្រជ្រៀតគ្នាតាំងពីព្រលឹមទៅមើល ទិញ ឬបង្ហាញស្នាដៃរបស់សហគមន៍អាស៊ីនៅទីក្រុងឡូវែលដ៏តូច




ពិធីបុណ្យអុំទូក បណ្តែតប្រទីប ប្រចាំឆ្នាំទី១៤
ບຸນຊ່ວງເຮືອ
งานแข่งเรือสายสัมพันธ์ประจำปีที่ 14





ដៃសមុទ្រ មេរីម៉ាក នាឱកាសបុណ្យអុំទូក

ហើយដាច់ស្រាយ៉ាលនេះ ។ គេអាចទិញសៀវភៅដែលកម្រមាន, ទិញថាសចម្រៀង ឬកុន, ទិញរូបផ្ទាំងគំនូរ, របស់តាំងលំអរផ្ទះតាមរបៀបអាស៊ី ទិញរហូតដល់បន្លែ ផ្លែឈើទៀតផង ។ ម្ហូបចំណីតាមទំនៀមទំលាប់បានត្រូវលក់ជាហូរហែរ ភេសជ្ជៈ ឬទឹកក្រឡុកដ៏ត្រជាក់ចិត្ត បានក្លាយជាទីចំណូលចិត្ត ដោយធាតុអាកាសថ្ងៃនេះ អំណោយផលដល់ពិធីបុណ្យនេះណាស់ ។

ឡូវែលនៃថ្ងៃទី២១ សីហានេះ បានផ្តល់កិត្តិយស និងលើកកំពស់តំបន់ញូអិនគ្លីននេះបានយ៉ាងខ្ពស់ អ្នករស់នៅ "លីន" ឬ "រីវែ" បានចូលរួមជាអ្នកចាប់ ផ្តើមបុណ្យយ៉ាងសកម្ម ។ អ្វីដែលគួរកត់សំគាល់នោះ គេឃើញសុទ្ធតែយុវជន ក្មេង ក្មេងជំទង់ (តទៅទំព័រទី ២០)

## វត្តព្រះពុទ្ធវង្សី ប្រារព្ធពីសម្ពោធក្លោងទ្វារ

**ដោយប្រភាព អ៊ឹម ឈឿម**

**ហ្វីឡាដែលហ្វៀ :** ពិធីបុណ្យសម្ពោធក្លោងទ្វារវត្តត្រូវបានប្រារព្ធធ្វើនៅថ្ងៃទី២១-២២ នាសប្តាហ៍កន្លងទៅនេះ ។ (តទៅទំព័រទី ១១)



ក្លោងទ្វារវត្តព្រះពុទ្ធវង្សី ទើបនឹងសាងសង់ថ្មី



ព្រះសង្ឃ និងពុទ្ធបរិស័ទជើងវត្ត



## កាសែតខ្មែរប៉ុស្តិ៍នៅញូអិនគ្លីន

•ខ្មែរប៉ុស្តិ៍ឆ្នេរខាងកើត កំពុងពង្រីកការចែកផ្សាយរបស់ខ្លួនកាលពីសប្តាហ៍មុននាឱកាសបុណ្យអុំទូកនៅឡូវែល ។ សាធារណជនខ្មែរ និងសាសន៍ដទៃបានទទួលស្វាគមន៍កាសែតយើងយ៉ាងកក់ក្តៅ ដែលស្មារតីនេះ យើងសុំថ្លែងការកោតសរសើរ និងអំណរគុណជាទីបំផុត ។ យើងធ្លាប់បានបំពេញតួនាទីជាសារព័ត៌មានប្រចាំសហគមន៍ខ្មែរ នៅតំបន់ផ្សេងៗនៃឆ្នេរខាងកើតសហរដ្ឋអាមេរិក ប្រកបដោយវិជ្ជាជីវៈជាច្រើនឆ្នាំ ហើយយើងនឹងបន្តបំរើវិស័យព័ត៌មាននៅឡូវែល និងតំបន់ជុំវិញ ដោយភក្តីភាពចំពោះលោកអ្នកអានគ្រប់ទិសទី ។

លោកអ្នកអានអាចបង្ហាញការគាំទ្រ ឬក៏មិនពេញចិត្តចំពោះយើង សូមទូរស័ព្ទទៅអ្នកគ្រប់គ្រងរដ្ឋបាល និងពាណិជ្ជកម្មរបស់យើង : លោក មាស សុផល : (978) 758 8547 ឬ Email : sophalUSA@gmail.com ឬសរសេរទៅអាស័យដ្ឋាន ខ្មែរប៉ុស្តិ៍ ឡូវែល : P.O Box 1318 Lowell, MA 01852. ។ សូមអរគុណ!







ភោជនីយដ្ឋានខ្មែរ
Kavei
CAMBODIAN RESTAURANT
Authentic Khmer • Thai • Lao • Vietnamese Phở
320 W OREGON AVENUE
(OREGON MARKET, SOUTH PHILLY)
215.952.6688
OPEN 7 DAYS A WEEK
9am-10pm
ត្រីចៀនជូន
• ភោជនីយដ្ឋានយើងខ្ញុំ ចាប់ផ្តើមបើកពីថ្ងៃហើយ!
• មានម្ហូបខ្មែរពិសេសៗជាច្រើនមុខ ម្ហូបថៃ ឡាវ និង ហ៊ើរៀតណាម
• មានទទួលសម្រាប់ពិធីជប់លាង ខួបកំណើត និង ពិធីផ្សេងៗ
• មានតន្ត្រីសម័យកំដរភ្ញៀវរាល់ល្ងាច ថ្ងៃសុក្រ-សៅរ៍-អាទិត្យ
• លោកអ្នកអាចទូរស័ព្ទមកកក់ទុកមុនបាន
• មានកន្លែងចតរថយន្ត ដ៏ធំទូលាយ
ញាំស្វាយខ្ចីបង្គា
អាម៉ុក
សម្លការី នំប៉័ង

# កម្ពុជា និងវិបត្តិដុល្លារភាវូបនិយកម្មក្នុងកិច្ចសហប្រតិបត្តិការ ជាមួយ យួន និងលាវ

ខ្មែរប៉ុស្តិ៍ : ចន្ទា • សុវណ្ណារ៉ា

•••កាលពីថ្ងៃទី6 ខែកក្កដា ឆ្នាំ2010 ធនាគារអភិវឌ្ឍន៍អាស៊ីបានចេញផ្សាយសៀវភៅមួយមានចំណងជើងថា "*ការដោះស្រាយបញ្ហាពហុរូបិយប័ណ្ណនៅក្នុងសេដ្ឋកិច្ចអន្តរកាល : វិសាលភាពសម្រាប់កិច្ចសហប្រតិបត្តិការនៅកម្ពុជា លាវ និង យួន*"។

សៀវថ្មីរបស់ធនាគារអភិវឌ្ឍន៍អាស៊ីបានលើកអនុសាសន៍ថា កិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធលើបញ្ហារូបិយវត្ថុ និងហិរញ្ញវត្ថុអាចនឹងជួយដល់ប្រទេសកម្ពុជា លាវ និងយួនដើម្បីដោះយ៉ាងមានប្រសិទ្ធភាពចំពោះការប្រឈមមុខនានា ដែលកើតឡើងពីការប្រើប្រាស់ពហុរូបិយប័ណ្ណនៅក្នុងវិស័យសេដ្ឋកិចផ្សេងៗគ្នារបស់គេ ។

សៀវភៅនេះបានលើកទឹកចិត្តឱ្យមានការចូលរួមគ្នាយ៉ាងជិតស្និទ្ធលើបញ្ហារូបិយវត្ថុ និងហិរញ្ញវត្ថុដែលអាចនឹងជួយដល់ប្រទេសចំនួន3នៅក្នុងសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ ឬ អាស៊ាន ដើម្បីបង្កើនទូវស្ថិរភាព និងបង្កើតឡើងនូវការអនុវត្តន៍ដ៏ប្រសើរបំផុត និងបទដ្ឋាននិយតកម្មទូទៅ ។ ការសន្ទនាកំរិតតំបន់ដ៏ជិតស្និទ្ធស្តីពីបញ្ហាទាំងនេះក៏អាចជួយដល់ប្រទេសកម្ពុជា លាវ និងយួន ក្នុងការធ្វើឱ្យល្អប្រសើរដល់ប្រសិទ្ធភាពនៃគោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់របស់គេ នៅខណៈដែលប្រមូលផលប្រយោជន៍បានច្រើនជាងនេះពីការកើនឡើងអន្តរា-និស្សរភាពសេដ្ឋកិច្ចរបស់ខ្លួន ។

ជាមួយគ្នានេះដែររូបិយប័ណ្ណក្នុងស្រុកប្រជាជនកម្ពុជា លាវ និងយួន ជាញឹកញាប់ប្រើប្រាស់រូបិយប័ណ្ណរបស់ប្រទេសផ្សេង ដើម្បីធ្វើសកម្មភាពពាណិជ្ជកម្ម ។


ដុល្លារអាមេរិក


កន្លែងដូរលក់

ប្រាក់ដុល្លារជារូបិយប័ណ្ណជំនួសដ៏សំខាន់មួយ ថ្វីត្បិតតែរូបិយប័ណ្ណផ្សេងទៀតក៏ត្រូវបានដាក់ឱ្យចរាចរយ៉ាងទូលំទូលាយផងដែរក៏ដោយដែលការអនុវត្តជាក់ស្តែងគេហៅថា "ដុល្លារភាវូបនិយកម្ម" ។ គេជឿថាការចែករំលែកនៃរូបិយប័ណ្ណបរទេសមានកំរិតចាប់ពីប្រមាណ 20% ក្នុងចំណោមរូបិយប័ណ្ណដែលដាក់ឱ្យចរាចរនៅយួនប្រមាណជា50% នៅលាវ និងជាង 90%នៅប្រទេសកម្ពុជា ។

ដុល្លារភាវូបនិយកម្មមានតម្លៃ និងផលប្រយោជន៍។ ដុល្លារភាវូបនិយកម្មអាចដាក់វិន័យលើរដ្ឋាភិបាលដោយហេតុថារដ្ឋាភិបាលមិនអាចផ្តត់ផ្គង់គុណវិបត្តិថវិកាបានងាយស្រួលតាមរយៈការបោះពុម្ពក្រដាសប្រាក់ និងយកពន្ធអាករថ្មីទៀតឡើយ ។ ប្រសិនជាដុល្លារភាវូបនិយកម្មនាំទៅជិតការកំណត់អត្រាប្តូរប្រាក់តម្លៃក៏អាចងាយផ្លាស់ប្តូរបំផុត ។ ទោះជាយ៉ាងនេះក្តី ការប្រើប្រាស់ពហុរូបិយប័ណ្ណអាចបណ្តាលឱ្យអាជ្ញាធរសេដ្ឋកិច្ចបាត់បង់ការគ្រប់គ្រងលើគោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់ ហើយវាក៏អាចដាក់កំរិតអំណាចរបស់ធនាគារកណ្តាលដែលជាអ្នកឱ្យខ្ចីប្រាក់ជាដំណោះស្រាយចុងក្រោយ ដោយបោះពុម្ពរូបិយប័ណ្ណតែមួយពីក្នុងចំណោមរូបិយប័ណ្ណជាច្រើនដែលសាធារណៈសុខចិត្តប្រើប្រាស់ និងរក្សាទុក ។

លោក ហ៊្គីអូវ៉ាន់នី ខេពផៃនណេលី អ្នកសេដ្ឋកិច្ចជាន់ខ្ពស់ប្រចាំធនាគារអភិវឌ្ឍន៍អាស៊ីនៃការិយាល័យសមាហរណកម្មសេដ្ឋកិច្ចតំបន់បានលើកឡើងនូវអនុសាសន៍ថា ការចែករំលែកព័ត៌មាន និងបទពិសោធន៍អាចនឹងជួយដល់អាជ្ញាធររូបិយវត្ថុកម្ពុជា លាវ និងយួន ដែលស្វែងរកដំណោះស្រាយចំពោះបញ្ហាដុល្លារភាវូបនិយកម្ម។ លោកបានបន្តសង្កត់ធ្ងន់ធ្ងរថាប្រទេសទាំងបីត្រូវពិចារណាអំពីកម្រិតផ្សេងៗគ្នានៃដុល្លារភាវូបនិយកម្មនៅក្នុងសេដ្ឋកិច្ចរបស់គេ និងព្យាយាមធ្វើឱ្យល្អប្រសើរដល់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ទាំងក្នុងចំណោមពួកគេ និងជាមួយសមា-ជិកអាស៊ានផ្សេងទៀត ។

សៀវភៅនេះបន្តលើកឡើងនូវអនុសាសន៍ទៀតថា សំណើនាពេលអនាគតសម្រាប់ក្របខណ្ឌរូបិយវត្ថុទូទៅ ឬអត្រាប្តូរប្រាក់ក្នុងចំណោមប្រទេសទាំងបីគួរតែពិចារណាលើពហុរូបិយប័ណ្ណដែលត្រូវបានប្រើប្រាស់នៅក្នុងសេដ្ឋកិច្ចរបស់ពួកគេ ។ សៀវភៅនេះក៏ឆ្លុះបញ្ចាំងពីសារសំខាន់នៃការតាមដានពិនិត្យមើលម៉ាក្រូសេដ្ឋកិច្ចតំបន់ដើម្បីការពារដល់ស្ថិរភាពហិរញ្ញ-វត្ថុ និងធានានូវគោលនយោបាយរូបិយវត្ថុ និងរបបអត្រាប្តូរប្រាក់នៅក្នុងប្រទេសទាំងបី ឱ្យមានសង្គតជាមួយគោលដៅអភិវឌ្ឍន៍សេដកិច្ចរយៈពេលយូរអង្វែងរបស់គេ ។

លោក ជេយ៉ាន មេនុន អ្នកសេដ្ឋកិច្ចជាន់ខ្ពស់នៃធនាគារអភិវឌ្ឍន៍អាស៊ី និងជាសហនិពន្ធសៀវភៅនេះបានលើកឡើងថា ដុល្លារភាវូបនិយកម្មធ្វើឱ្យរិលដល់ឧបករណ៍សម្រាប់ស្ថិរភាពភាវូបនិយកម្មម៉ាក្រូសេដ្ឋកិច្ច ជាពិសេសគោល នយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់ដែលប្រទេសកម្ពុជា លាវ និងយួនត្រូវដោះស្រាយលើភាពផ្សេងគ្នានៃបញ្ហាសេដ្ឋកិច្ច និងអភិវឌ្ឍន៍ មានជាអាទិ៍អតិផរណាធ្ងន់ធ្ងរ ។ ការកែសម្រួលឱ្យសមស្របចំពោះវិបត្តិខាងក្រៅក៏អាចត្រូវបានបន្តរយៈពេលយូរច្រើនជាងនេះ និងការឈឺចាប់នៅក្នុងវត្តមានបាតុភូតពហុរូបិយប័ណ្ណ ។

រូបិយប័ណ្ណដុល្លារត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅប្រទេសកម្ពុជា បន្ថែមពីលើរូបិយបណ្ណជាតិគឺ "រៀល" របស់ខ្លួន ។ នៅប្រទេល លាវ រូបិយប័ណ្ណគីប (Kip) ត្រូវបានប្រើប្រាស់ជាមួយរូបិយប័ណ្ណដុល្លារ និងប្រាក់បាត ។ នៅប្រទេសយួនប្រាក់ឌុងជារូបិយប័ណ្ណផ្លូវការតែមួយគត់ ប៉ុន្តែរូបិយប័ណ្ណដុល្លារអាចត្រូវបានប្រើប្រាស់ជាការប្រមូលសន្សំទុក ។

រដ្ឋាភិបាលកម្ពុជាបានចំណាយពេលជិតមួយទសវត្សរ៍ក្នុងកិច្ចខំប្រឹងប្រែងដើម្បីលុបបំបាត់រូបិយប័ណ្ណដុល្លារពីវិស័យសេដ្ឋកិច្ចរបស់ខ្លួន ប៉ុន្តែកម្ពុជានៅតែជាប្រទេសមួយដែលចរាចររូបិយប័ណ្ណដុល្លារនៅក្នុងវិស័យសេដ្ឋកិច្ចច្រើនជាងគេបំផុតនៅក្នុងពិភពលោក ។

អ្នកជំនាញបានលើកឡើងថា រូបិយប័ណ្ណអាមេរិកត្រូវបានប្រើប្រាស់ជិត90ភាគរយនៅក្នុងជំនួញស្របគ្នាជាមួយរូបិយប័ណ្ណក្នុងស្រុកគឺ "រៀល/៛" ហើយការផ្លាស់ប្តូរនឹងមិនអាចធ្វើទៅបានទេ បើគ្មានកំណែទម្រង់ផ្នែករដ្ឋបាលឱ្យបានច្រើនទេនោះ ។ នៅពេលជាមួយគ្នាប្រជាពលរដ្ឋខ្មែរមិនមានការជឿជាក់នៅក្នុងប្រាក់រៀល ដោយហេតុថា ប្រាក់រៀលបានទទួលរងអតិផរណាកាលពីពេលថ្មីៗនេះ ដែលធ្វើឱ្យប្រាក់ដុល្លារមានការទាក់ទាញច្រើន។ គេនៅចាំបានថាប្រាក់ដុល្លារបានហូរចូលមកកម្ពុជាយ៉ាងច្រើនសន្ធឹកសន្ធាប់នៅឆ្នាំ1992 នៅពេលអង្គការសហប្រជាជាតិបានមកបំពេញបេសកកម្មរៀបចំការបោះឆ្នោតជាលើកដំបូងក្នុងរយៈពេល21ឆ្នាំ បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ខែតុលា ឆ្នាំ1991 ដែលបានបញ្ចប់សង្គ្រាមស៊ីវិលជាង2ទសវត្សរ៍រួចមក ។ អង្គការសហប្រជាជាតិ តាមរយៈអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំកម្ពុជា (អ៊ុនតាក់) បានចំណាយ ប្រាក់ចំនួន2កោដិដុល្លារក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួននៅកម្ពុជា ។ (តទៅលេខក្រោយ)



ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ
សេវាលិខិតឆ្លងដែន
សេវាអន្តោប្រវេសន៍
កក់សណ្ឋាគារ ឬជួលឡាន

USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO

angkortravelphilly@yahoo.com

Cambodia Office: Victory Travel (Skin Belle)
No 57B, Eo Street 205 Touls Svay Prey 2.
Phnom Penh, Cambodia.
Ms. Chenda: 023-221069 * 012-851575
Or Mr. Sin Po: 012 429407 * 011-541111.

SERVING SINGAPOR, EVA AIR,
KOREAN AIRLINES, MALAYSIA etc...

*My Health.*
*My Medicare.*

## មជ្ឈមណ្ឌលចាត់ចែងសេវាធានារ៉ាប់រងសុខភាព មេឌីខេដ (Medicaid) និង មេឌីឃែ (Medicare)
## គ្រឿងផ្សាយព័ត៌មានតាមវិធីផ្សេងៗអំពី មេឌីឃែ (Medicare) និង ការឃោសនាអប់រំជាតិ

### លោកអ្នកប្រហែលជាអាចទទួលកម្មវិធី មេឌីឃែ (Medicare)
### ដែលលោកអ្នកត្រូវចេញថ្លៃត្រឹមតែ $2.40 សម្រាប់ថ្នាំដែលត្រូវការវេជ្ជបញ្ជា

អស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ លោកអ្នកបានប្រើអ្វីៗដែលលោកអ្នកត្រូវធ្វើជាស្រេច គឺឥតបង់ប្រាក់សម្រាប់ មេឌីឃែ (Medicare) ។ ឥឡូវនេះ ដល់វេនលោកអ្នកអាចទទួលអត្ថប្រយោជន៍ ដែលលោកអ្នកបានសន្សំទុកនោះវិញ ។ ប្រសិនបើលោកអ្នកមានប្រាក់ចំណូល និងធនធានមិនហួសពីកម្រិតដែលរដ្ឋបានកំណត់ មានកម្មវិធី មេឌីឃែ ដែលលោកជួយចេញថ្លៃមិនលើសពី $2.40 សម្រាប់ថ្នាំទូទៅ(genericdrug) និង $ 6 សម្រាប់ថ្នាំដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនណាមួយ (brand name drug) ។

ប្រសិនបើលោកអ្នកអាចទទួលកម្មវិធីនេះ នឹងជួយបង់ថ្លៃទិញថ្នាំបន្តិចបន្តួចទៅលើចំនួនដែលក្រុម ហ៊ុនធានារ៉ាប់រងបង់ឱ្យ(prescription copayments) រួមទាំងថ្លៃថ្នាំដ៏ទៃៗទៀតរបស់លោកអ្នក ដូចជាប្រាក់បង់ថ្លៃធានារ៉ាប់រងសុខភាពប្រចាំខែ (monthly premiums) និងប្រាក់ដែលក្រុមហ៊ុនធានារ៉ាប់រងដកយកបន្តិចបន្តួចប្រចាំឆ្នាំ (annual deductibles) ។ ប្រជាជនជាច្រើនអាចទទួល ប៉ុន្តែមិនដឹងថា ពួកគេមានសិទ្ធិទទួល ។

បុគ្គលម្នាក់ដែលមានប្រាក់ចំណូលក្រោម $16 ,245 និងប្តីប្រពន្ធដែលមានប្រាក់ចំណូលក្រោម $21 ,855 ប្រហែលជាមានសិទ្ធិបញ្ចុះថ្លៃធានារ៉ាប់រង សម្រាប់ថ្នាំដែលត្រូវការវេជ្ជបញ្ជា ថ្លៃជួយចេញបន្តិចបន្តួច និងប្រាក់ដែលក្រុមហ៊ុនធានារ៉ាប់រងដកយកបន្តិចបន្តួច ។ ដើម្បីមានសិទ្ធិទទួលធនធានរបស់ បុគ្គលទាំងនេះត្រូវមានកម្រិតត្រឹមតែ ($12,510ឬ $25,010 សម្រាប់ប្តីប្រពន្ធ ។ ធនធានគឺរាប់ទាំងប្រាក់ដែលមានក្នុងធនាគារ ភាគហ៊ុន និងប្រាក់ឱ្យគេខ្ចីដើម្បីយកការ ប៉ុន្តែមិនមែនជាផ្ទះ ឬរថយន្តរបស់លោកអ្នកទេ ។

ការដាក់ពាក្យសុំសម្រាប់កម្មវិធីនេះ ធ្វើឡើងដោយឥតគិតថ្លៃ ។ ដាក់ពាក្យសុំតាមកុំព្យូទ័រ www.socialsecurity.gov ឬទូរស័ព្ទទៅក្រសួងសន្តិសុខសង្គម(Social security) លេខ១-៨០០-៧៧២-១២១៣ (អ្នកប្រើម៉ាស៊ីន TTY គួរទូរស័ព្ទទៅលេខ ១-៨០០-៣២៥-០៧៧៨) ហើយ ស្នើសុំពាក្យជំនួយសម្រាប់ថ្លៃទិញថ្នាំដែលត្រូវការវេជ្ជបញ្ជា ។ ព័ត៌មានទាំងអស់ដែលបានផ្តល់ឱ្យក្នុងពាក្យសុំនេះ ត្រូវគេរក្សាទុកជាសម្ងាត់ ។

ប្រសិនបើលោកអ្នកមានប្រាក់ចំណូលតែបន្តិចបន្តួច លោកអ្នកដឹងថា ជួនកាលមានការលំបាកក្នុងការសម្រេចចិត្តធ្វើអ្វីមួយនៅផ្ទះ ។ នោះមិនមែនមានន័យថា មិនបាច់លេបថ្នាំរបស់លោកអ្នកនោះទេ ។ សូមដាក់ពាក្យសុំពីឥឡូវនេះទៅ ដើម្បីធ្វើឱ្យប្រាកដថា លោកអ្នកមានថ្នាំដែលត្រូវការវេជ្ជបញ្ជា ដែលលោកអ្នកត្រូវការឱ្យនៅមានសុខភាពល្អ ហើយអាចធ្វើអ្វីៗដែលលោកអ្នកចូលចិត្តធ្វើតទៅទៀត ។

ដើម្បីជ្រាបបន្ថែមអំពី គម្រោងទិញថ្នាំដែល ត្រូវការវេជ្ជបញ្ជានិងពេលដែលលោកអ្នកអាចចូលរួមបានសូមទូរស័ព្ទទៅលេខ ១-៨០០ MEDI CARE (១-៨០០-៦៣៣-៤២២៧) ឬម៉ាស៊ីន TTY ១-៨៧៧-៤៨៦-២០៤៨) ឬមើលតាមវិបសៃ www.medicare.gov ។

ព័ត៌មាននេះបានរៀបចំឡើងដោយ U.S Department of Health and Human Services ។

## មជ្ឈមណ្ឌលចាត់ចែងសេវាធានារ៉ាប់រងសុខភាពមេឌីខេដ (MEDICAID) និងមេឌីឃែ (MEDICARE)

### តើ មេឌីឃែ (MEDICARE) ជាអ្វី ?

មេឌីឃែ (MEDICARE) គឺជាការធានារ៉ាប់ រងសុខភាព សម្រាប់ប្រជាពលរដ្ឋដែលមានអាយុ ៦៥ ឆ្នាំឡើងទៅ អ្នកដែលមានអាយុក្រោម៦៥ ឆ្នាំ ដែលមានភាពពិការអ្វីមួយ និងអាយុប៉ុន្មានក៏បាន បើខូចតម្រងនោមជាអចិន្ត្រៃយ៍ (ហៅថា "End-Stage Renal Disease") ។ លោកអ្នកត្រូវមានសិទ្ធិ មករស់នៅសហរដ្ឋត្រឹមត្រូវតាមច្បាប់ ហើយបានរស់នៅទីនេះអស់រយៈពេល៥ឆ្នាំ ទើបមានសិទ្ធិទទួលមេឌីឃែ ។

**មេឌីឃែ (MEDICARE) មានពីផ្នែក :**

#### មេឌីឃែ Part A (ការធានារ៉ាប់រងថ្លៃគេងពេទ្យ)

ជួយបង់ថ្លៃសម្រាប់ពេលគេងពេទ្យ កន្លែង មើលថែចាស់ព្រឹទ្ធាចារ្យ ឬអ្នកជម្ងឺ ឬកន្លែងជួយសម្រាលអ្នកមានជម្ងឺផ្សេងៗ និងសម្រាប់ការព្យាបាលនៅផ្ទះ ប្រសិនបើលោកអ្នកមានលក្ខណៈតាមការតម្រូវ ។ ពលរដ្ឋភាគច្រើនមិនចាំបាច់បង់ថ្លៃធានារ៉ាប់រងប្រចាំខែសម្រាប់ មេឌីឃែ Part A ទេ ពីព្រោះពួកគេ ឬប្តីប្រពន្ធគេ បានបង់ប្រព័ន្ធសម្រាប់ មេឌីឃែ រួចទៅហើយ នៅពេលដែលពួកគេធ្វើការនៅសហរដ្ឋ ។ ប្រសិនបើលោកអ្នកមិនទទួល ការធានារ៉ាប់រង Part A ដែលឥតបង់ថ្លៃដោយស្វ័យប្រវត្តិ លោកអ្នកប្រហែលនៅតែអាចចុះឈ្មោះ បានតែត្រូវបង់ថ្លៃធានារ៉ាប់រងប្រចាំខែ ។

#### មេឌីឃែ Part B (ការធានារ៉ាប់រងថ្លៃព្យាបាលទូទៅ)

ជួយបង់ថ្លៃនៅពេលចាំបាច់ត្រូវព្យាបាលដោយវេជ្ជបណ្ឌិត និងការព្យាបាលដោយមិនចាំបាច់គេង នៅមន្ទីរពេទ្យផ្សេងទៀត ។ ហើយក៏អាចជួយបង់ ថ្លៃសម្រាប់ការការពារខ្លះៗ(ដូចជាចាក់ថ្នាំបង្ការ រោគផ្តាសាយ) ដើម្បីជួយលោកអ្នកឱ្យនៅមានសុខភាពល្អ ហើយជួនកាលអាចជួយការពារមិនឱ្យមានជម្ងឺធ្ងន់ធ្ងរ ។ ពលរដ្ឋភាគច្រើនបង់ថ្លៃធានារ៉ាប់រង ប្រចាំខែធម្មតា សម្រាប់ មេឌីឃែ Part B (ឆ្នាំ២០០៨ មានតម្លៃ $96.40) ។

## លោកអ្នកអាចជ្រើសរើសរបៀបដែល មេឌីឃែ ចេញថ្លៃឱ្យលោកអ្នក ។ នេះគឺជាជម្រើសសំខាន់ពី :

**មេឌីឃែ ដើមដំបូង(Original Medicare)**

ចាត់ចែងដោយរដ្ឋាភិបាល ចេញថ្លៃ មេឌីឃែ Part A និង Part B ឱ្យលោកអ្នក ។ (លោកអ្នកអាចរើសយកតែមួយ ឬទាំងពីរផ្នែក) លោកអ្នកត្រូវតែចេញថ្លៃក្រុមហ៊ុនធានារ៉ាប់រងដកយកបន្តិចបន្តួច (Deductible) ហើយតាមធម្មតា លោកអ្នកត្រូវជួយចេញថ្លៃមួយចំណែកតាមកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនធានារ៉ាប់រង និងលោកអ្នក (coinsurance) នៅពេលលោកអ្នកទទួលការព្យាបាលម្តងៗ ។

១-លោកអ្នកអាចបន្ថែម មេឌីឃែ Part D ដែលចេញថ្លៃទិញថ្នាំដែលត្រូវការវេជ្ជបញ្ជា ដោយចូលរួមជាមួយ មេឌីឃែ ដែលរ៉ាប់រងចេញថ្លៃទិញថ្នាំ ដែលត្រូវការវេជ្ជបញ្ជា ។ តម្លៃនិងអត្ថប្រយោជន៍ ខុសគ្នាពីគម្រោងធានារ៉ាប់រងមួយនៅគម្រោងធានារ៉ាប់រងមួយទៀត ។

២-លោកអ្នកអាចជ្រើសរើសទិញប័ណ្ណសន្យាធានារ៉ាប់រង មេឌីហ្គែព (Medigap)(ជាមេឌីឃែ ដែលធានារ៉ាប់រងបន្ថែម) ដើម្បីជួយបង់ថ្លៃសម្រាប់ការព្យាបាលខ្លះៗ" ហ្គែពស្ស៍-gaps" (ដូចជាបង់ថ្លៃព្យាបាលជម្ងឺបន្តិចបន្តួចបន្ថែមទៅលើចំនួនដែលបង់ដោយក្រុមហ៊ុនធានារ៉ាប់រង(copayments) ចេញមួយចំណែកតាមកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនធានារ៉ាប់រង និងលោកអ្នក(coinsurances) និងប្រាក់ដែលក្រុមហ៊ុនធានារ៉ាប់រងដកហូតបន្តិចបន្តួចមុននិងចេញឱ្យពេញចំនួន(deductibles) ។

**គម្រោង មេឌីឃែផ្សេងៗទៀត(ហៅថា Part C)**

លោកអ្នកត្រូវតែមាន Part A និង Part B ទើបអាចចូលរួមជាមួយគម្រោងមួយក្នុងចំណោមទាំងនេះបាន ។ គម្រោងនេះផ្ដល់ការធានារ៉ាប់រងទាំងអស់ ដូចគ្នានឹង Part A និង Part B ហើយជាទូទៅផ្ដល់សេវាផ្សេងៗបន្ថែមទៀត ។ តាមធម្មតា លោកអ្នកបង់ថ្លៃធានារ៉ាប់រងប្រចាំខែ និងបង់ថ្លៃព្យាបាលជម្ងឺបន្តិចបន្តួចបន្ថែមទៅលើចំនួនដែលបង់ដោយក្រុមហ៊ុនធានារ៉ាប់រង (conayments) ដែលថោក ជាងថ្លៃដែលលោកអ្នកជួយចេញមួយចំណែកតាមកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនធានារ៉ាប់រង និងលោកអ្នក(coinsurances) និងប្រាក់ដែលក្រុមហ៊ុនធានារ៉ាប់រងដកហូតបន្តិចបន្តួចមុននឹងសងពេញចំនួន(deductibles) ក្រោមការធានារ៉ាប់រងរបស់ មេឌីឃែ ដើមដំបូង(Original Medicare) ។ ភាគច្រើន គម្រោងធានារ៉ាប់រងទាំងនេះក៏ផ្ដល់ Part D ដែលជាគម្រោងចេញថ្លៃទិញថ្នាំដែលត្រូវការវេជ្ជបញ្ជាឱ្យដែរ ។ ការធានារ៉ាប់រងទាំងនេះ ត្រូវផ្ដល់ជូនដោយក្រុមហ៊ុនធានារ៉ាប់រងឯកជន ដែលបានយល់ព្រមដោយ មេឌីឃែ ។ តម្លៃ និងអត្ថប្រយោជន៍ ខុសគ្នាពីគម្រោងធានារ៉ាប់រងមួយទៅគម្រោងធានារ៉ាប់រងមួយទៀត ។

**ការកត់សម្គាល់ :** មានជំនួយសម្រាប់លោកអ្នក បើលោកអ្នកមានប្រាក់ចំណូល និងធនធាន តែបន្តិចបន្តួច លោកអ្នកប្រហែលជាមានសិទ្ធិទទួលជំនួយសម្រាប់បង់ថ្លៃព្យាបាល មេឌីឃែ របស់លោកអ្នក និង /ឬថ្លៃទិញថ្នាំដែលត្រូវការវេជ្ជបញ្ជា ។ ដើម្បីជ្រាបព័ត៌មានបន្ថែមសូមទូរស័ព្ទទៅក្រសួងសូស្យាល់សិខ្យូរីធី(Social Security) លេខ ១-៨០០-១២១៣ មើលតាមវ៉ិបសៃ www.socialsecurity.gov ឬដាក់ពាក្យសុំទៅការិយាល័យផ្ដល់ជំនួយធានារ៉ាប់រងសុខភាពរដ្ឋមេឌីខេដ (Med icaid) ។ បើលោកអ្នកមានសំណួរអំពី មេឌីឃែ (Medicare) ឬអំពី មេឌីឃែ ដែលចេញថ្លៃព្យាបាល និងថ្លៃទិញថ្នាំដែលត្រូវការវេជ្ជបញ្ជា នៅតាមតំបន់របស់លោកអ្នក សូមមើលតាមវ៉ិបសៃ www. medicare.gov ឬទូរស័ព្ទទៅ ១-៨០០-MEDICARE (១-៨០០-៦៣៣-៤២២៧) ។ អ្នកប្រើម៉ាស៊ីន TTY គួរទូរស័ព្ទទៅលេខ ១-៨៧៧-៤៨៦-២០៤៨ ។

# មជ្ឈមណ្ឌលចាត់ចែងសេវាធានារ៉ាប់រងសុខភាព មេឌីខេដ (MEDICAID) និងមេឌីឃែ (MEDICARE)

**តើ មេឌីខេដ(Medicaid) ជាអ្វី ?**

មេឌីខេដ (Medicaid) គឺជាការធានារ៉ាប់រងសុខភាពសម្រាប់ពលរដ្ឋ និងក្រុមគ្រួសារដែលមានប្រាក់ចំណូល និងធនធានតែបន្តិចបន្តួច ។ ក្បួនវិន័យសម្រាប់រាប់ប្រាក់ចំណូល និង ធនធានរបស់លោកអ្នក(ដូចជាប្រាក់ទុកនៅធនាគារ ឬរបស់ផ្សេងៗទៀត ដែលអាចលក់យកជាប្រាក់បាន) តាមធម្មតាយោងទៅតាមរដ្ឋដែលលោកអ្នករស់នៅ ។ សិទ្ធិទទួលក៏ប្រហែលយោងទៅលើអាយុរបស់លោកអ្នក ហើយថាតើអ្នកមានផ្ទៃពោះ ខ្វាក់ ឬមានភាពពិការអ្វីមួយ ហើយថាតើលោកអ្នកជាសញ្ជាតិអាមេរិក ឬជាជនអន្តោប្រវេសន៍ដែលមករស់នៅត្រឹមត្រូវតាមច្បាប់ ឬអត់ ។ ប្រសិនបើ មេឌីខេដ ចេញថ្លៃឱ្យស្ត្រីដែលឈឺពោះ និងឆ្លងទន្លេ ទារករបស់គេប្រហែលជាទទួលការចេញថ្លៃឱ្យរហូតដល់ទៅ១ឆ្នាំ ដោយមិនចាំបាច់ដាក់ពាក្យសុំ ។

ទោះជាលោកអ្នកមិនប្រាកដថា លោកអ្នកមានសិទ្ធិទទួលឬអត់ក៏ដោយ ប្រសិនបើលោកអ្នកមានប្រាក់ចំណូលតែបន្តិចបន្តួច ហើយប្រសិនបើលោកអ្នក ឬអ្នកណាម្នាក់ដែលរស់នៅក្នុងគ្រួសារត្រូវការព្យាបាល លោកអ្នកគួរដាក់ពាក្យសុំ មេឌីខេដ ហើយទុកឱ្យអ្នកកាន់សំណុំរឿងដែលមានការចេះ ដឹងនៅរដ្ឋរបស់លោកអ្នក ធ្វើការពិនិត្យមើលស្ថានភាពរបស់លោកអ្នក ។

ពលរដ្ឋដែលមាន មេឌីខេដ ក៏ប្រហែលជាអាចទទួលការបង់ថ្លៃឱ្យសម្រាប់សេវាផ្សេងៗបានដែរ ដូចជាការមើលថែមនុស្សចាស់ និងអ្នកជម្ងឺ ។ យោងទៅតាមច្បាប់នៅរដ្ឋរបស់លោកអ្នក លោកអ្នកក៏ប្រហែលជាអាចត្រូវគេស្នើសុំឱ្យចេញថ្លៃមួយចំនួនតូច (copayment) សម្រាប់ការព្យាបាលខ្លះៗ ប្រសិនបើលោកអ្នកមានសិទ្ធិទទួល មេឌីឃែ និងមេឌីខេដ គេនឹងចេញថ្លៃព្យាបាលឱ្យលោកអ្នក ដល់ការព្យាបាលជាច្រើន ។

ប្រសិនបើលោកអ្នកមានសំណួរអំពី មេឌីខេដ (ស្វែងយល់ថា តើលោកអ្នកមានសិទ្ធិទទួលឬអត់ ឬចុះឈ្មោះដើម្បីចូលរួម) លោកអ្នកអាចទូរស័ព្ទ ទៅការិយាល័យផ្ដល់ជំនួយការធានារ៉ាប់រងសុខភាពនៅរដ្ឋរបស់លោកអ្នក(មេឌីខេដ) ដើម្បីជ្រាបព័ត៌មានបន្ថែម ។ មើលតាម វ៉ិបសៃ www.medicare. gov ។ សូមរកមើលពាក្យ Search Tools រួចចុចលើពាក្យ Find Helpful Phone Numbers and Websites ឬទូរស័ព្ទទៅលេខ ១-៨០០-MEDI CARE (១-៨០០-៦៣៣-៤២២៧) ដើម្បីសុំលេខទូរស័ព្ទ ។ អ្នកប្រើម៉ាស៊ីន TTY គួរទូរស័ព្ទទៅលេខ ១-៨៧៧-៤៨៦-២០៤៨ ។

អស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ លោកអ្នកបានប្រើអ្វីៗដែលលោកអ្នកត្រូវធ្វើជាស្រេច គឺឥតបង់ប្រាក់សម្រាប់ មេឌីឃែ (Medicare) ។ ឥឡូវនេះ ដល់វេនលោកអ្នកអាចទទួលអត្ថប្រយោជន៍ ដែលលោកអ្នកបានសន្សំទុកនោះវិញ ។ ប្រសិនបើលោកអ្នកមានប្រាក់ចំណូល និងធនធានមិនហួសពីកម្រិតដែលរដ្ឋបានកំណត់ មានកម្មវិធី មេឌីឃែ ដែលលោកជួយចេញថ្លៃមិនលើសពី $2.40 សម្រាប់ថ្នាំទូទៅ(genericdrug) និង $ 6 សម្រាប់ថ្នាំដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនណាមួយ (brand name drug) ។

ប្រសិនបើលោកអ្នកអាចទទួលកម្មវិធីនេះ នឹងជួយបង់ថ្លៃទិញថ្នាំបន្តិចបន្តួចទៅលើចំនួនដែលក្រុម ហ៊ុនធានារ៉ាប់រងបង់ឱ្យ(prescription copayments) រួមទាំងថ្លៃថ្នាំដទៃទៀតរបស់លោកអ្នក ដូចជាប្រាក់បង់ថ្លៃធានារ៉ាប់រងសុខភាពប្រចាំខែ (monthly premiums) និងប្រាក់ដែលក្រុមហ៊ុនធានារ៉ាប់រងដកយកបន្តិចបន្តួចប្រចាំឆ្នាំ (annual deductibles) ។ ប្រជាជនជាច្រើនអាចទទួល ប៉ុន្តែមិនដឹងថា ពួកគេមានសិទ្ធិទទួល ។

បុគ្គលម្នាក់ដែលមានប្រាក់ចំណូលក្រោម $16 ,245 និងប្ដីប្រពន្ធដែលមានប្រាក់ចំណូលក្រោម $21 ,855 ប្រហែលជាមានសិទ្ធិបញ្ចុះថ្លៃធានារ៉ាប់រង សម្រាប់ថ្នាំដែលត្រូវការវេជ្ជបញ្ជា ថ្លៃជួយចេញបន្តិចបន្តួច និងប្រាក់ដែលក្រុមហ៊ុនធានារ៉ាប់រងដកយកបន្តិចបន្តួច ។ ដើម្បីមានសិទ្ធិទទួលធនធានរបស់ បុគ្គលទាំងនេះត្រូវមានកម្រិតត្រឹមតែ ($12,510ឬ $25,010 សម្រាប់ប្ដីប្រពន្ធ ។ ធនធានគឺរាប់ទាំងប្រាក់ដែលមានក្នុងធនាគារ ភាគហ៊ុន និងប្រាក់ឱ្យគេខ្ចីដើម្បីយកការ ប៉ុន្តែមិនមែនជាផ្ទះ ឬរថយន្តរបស់លោកអ្នកទេ ។

ការដាក់ពាក្យសុំសម្រាប់កម្មវិធីនេះ ធ្វើឡើងដោយឥតគិតថ្លៃ ។ ដាក់ពាក្យសុំតាមកុំព្យូទ័រ www.socialsecurity.gov ឬទូរស័ព្ទទៅក្រសួងសូស្យាល់សិខ្យូរីធី(Social security) លេខ១-៨០០-៧៧២-១២១៣ (អ្នកប្រើម៉ាស៊ីន TTY គួរទូរស័ព្ទទៅលេខ ១-៨០០-៣២៥-០៧៧៨) ហើយ ស្នើសុំពាក្យជំនួយសម្រាប់ថ្លៃទិញថ្នាំដែលត្រូវការវេជ្ជបញ្ជា ។ ព័ត៌មានទាំងអស់ដែលបានផ្ដល់ឱ្យក្នុងពាក្យសុំនេះ ត្រូវគេរក្សាទុកជាសម្ងាត់ ។

ប្រសិនបើលោកអ្នកមានប្រាក់ចំណូលតែបន្តិចបន្តួច លោកអ្នកដឹងថា ជួនកាលមានការលំបាកក្នុងការសម្រេចចិត្តធ្វើអ្វីមួយនៅផ្ទះ ។ នោះមិនមែនមានន័យថា មិនបាច់លេបថ្នាំរបស់លោកអ្នកនោះទេ ។ សូមដាក់ពាក្យសុំពីឥឡូវនេះទៅ ដើម្បីធ្វើឱ្យប្រាកដថា លោកអ្នកមានថ្នាំដែលត្រូវការវេជ្ជបញ្ជា ដែលលោកអ្នកត្រូវការឱ្យនៅមានសុខភាពល្អ ហើយអាចធ្វើអ្វីៗដែលលោកអ្នកចូលចិត្តធ្វើតទៅទៀត ។

ដើម្បីជ្រាបបន្ថែមអំពីគម្រោងទិញថ្នាំដែលត្រូវការវេជ្ជបញ្ជានិងពេលដែលលោកអ្នកអាចចូលរួមបានសូមទូរស័ព្ទទៅលេខ ១-៨០០ MEDICARE (១-៨០០-៦៣៣-៤២២៧) ឬម៉ាស៊ីន TTY ១-៨៧៧-៤៨៦-២០៤៨) ឬមើលតាមវ៉ិបសៃ www.medicare.gov ។ ព័ត៌មាននេះបានរៀបចំឡើងដោយ U.S Department of Health and Human Services ៕

CMS Publication No. 11306

ខែមេសា ឆ្នាំ ២០០៨

សុខភាពរបស់ខ្ញុំ
មេឌីឃែរបស់ខ្ញុំ

# A.B.C MONEY TRANSACTION, INC

# $ ក្រុមហ៊ុនផ្ញើប្រាក់ A.B.C

## តម្លៃសំរាប់ផ្ញើទៅស្រុកខ្មែរ



| | | ភ្នំពេញ | តាមខេត្ត |
|---|---|---|---|
| ផ្ញើ $100 | យកកម្រៃ | $4.50 | $5.50 |
| $200 | យកកម្រៃ | $9.00 | $11.00 |
| $300 | យកកម្រៃ | $13.50 | $16.50 |
| $500 | យកកម្រៃ | $16.00 | $17.00 |
| $1000 | យកកម្រៃ | $25.00 | $26.00 |
| $1500 | យកកម្រៃ | $35.00 | $36.00 |
| $2000 | យកកម្រៃ | $42.00 | $43.00 |
| $2200 | យកកម្រៃ | $46.00 | $47.00 |

សូមកុំភ្លេចទាក់ទងការិយាល័យក្រុមហ៊ុន ABC ដែលនៅជិតលោកអ្នក ប្រសិនបើមានបំណងចង់ផ្ញើប្រាក់ទៅស្រុកខ្មែរ ឬក៏ទូរស័ព្ទមកយើងតាម

### នៅរដ្ឋ VIRGINIA សូមទាក់ទង

**ABC MONEY TRANSATION ,INC.**

8 locations to serve you in Virginia

- 6757 Willson Blvd.-Ste.#25 Tel : 703.534.2600
- 4291 Holland Rd-Ste.#111 Tel : 757.474.9400
- 10428 Ridgefield Pkwy Tel : 804-740-2454
- 2519 W . Mercury Blvd . Tel : 757.265.6305
- 23520 Overland Dr. Tel : 703.661.6666
- 6314 Rigsby Rd. Tel : 804.288.2988
- 7252 Arlingston Blvd . Tel : 703.641.0778
- 6217 W. Broad St. Tel : 804.288.6988

**ARIZONA**

◆4215 N 19th Ave. . Tel : 602.266.6744

**GEOERGIA**

◆ 4897 Buford Hwy. Ste. 202. Tel: 770.457.7888

**ILLINOIS**

◆4871 N. Broadway . Tel :773.989.7332

**MASSACHUSETTE**

◆ 996 Dorchester Ave. Tel:617.825.9380

◆ 1365-1377 Dorchester Ave. -Ste.4,Froor 1 . Tel : 617.265.4600

**MINNESOTA**

◆ 2718 Nicollet Ave . S.- Ste. 102 B

◆ Tel : 612.871.4731

◆ 6350 Brooklyn Blvd . Tel : 763.503.3947

**NORTH CAROLINA**

◆ 3000 Central Ave. Ste . #9 . Tel : 704-532-4420

**OREGON**

◆6908 N.E. Sandy Blvd . Tel : 503.281.8088

**PHILADFELPHIA**

◆5520 . Whitaker Ave. -Unit 2 . Tel : 215.831.9794

◆571 Adams Ave . Ave.#4 . Tel : 215.342.6623

**TEXAS**

◆1818 E . Pioneer Pkwy. Ste.156 . Tel : 317.461.1461

◆2615 W . Pioneer Pkwy. Ste.136 . Tel : 214.788.2817

◆5302 E . Belknap St.- Ste.D6 . Tel : 817.831.4836

◆3538 W . Walnut St. Tel : 972.272.2253

◆11205 Bellaire Blvd . Tel : 281.561.6600

◆10909 Scarsdale Blvd . Tel : 281.481.2700

◆13480 Veterans Memorial Dr.-Ste. F2. Tel: 281.587.0807

**WASHINTON STATE**

◆766 S.38th St,. Tel : 253.475.2847

◆3818 S.Graham St.-Ste. C Tel : 206.721.2070

Office : 714-590-8740 Fax : 714-590-8776
Cell: 714-603-3509 Toll Free : 1-877-939-0110

## ក្រុមហ៊ុនទទួលផ្ញើប្រាក់ទៅកម្ពុជា

ABC ជាក្រុមហ៊ុនផ្ញើប្រាក់តែមួយគត់នៅស្រុកខ្មែរ ដែលមានការប្រគល់ប្រាក់ដល់ផ្ទះ

- ស្របច្បាប់
- រហ័សទាន់ចិត្ត
- ធានារ៉ាប់រង និងជូនប្រាក់ទៅដល់ផ្ទះ
- កំរៃផ្ញើថោកជាងកន្លែងដទៃ

### ក្រៅពីការផ្ញើប្រាក់ក្រុមហ៊ុនមានលក់

PHONE CARD និង PINLESS សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ដែលផលិតដោយក្រុមហ៊ុន ABC ផ្ទាល់ មានគុណភាពល្អ ហើយជាពិសេស CARD របស់យើងនឹងទុកបានរហូត មិនអស់កំណត់កាលឡើយ ( NEVER EXPIRED) ។

ត្រូវការអ្នកសហការ (AGENTS ) ជាមួយយើងទូទាំងសហរដ្ឋអាមេរិក និងបានទទួលប្រាក់ចំណូលយ៉ាងខ្ពស់ !

ព័ត៌មានបន្ថែមសូមទាក់ទង CHET THACTHER តាមទូរស័ព្ទ និងអាស័យដ្ឋានខាងក្រោម :

ABC MONEY TRANSATION, INC
12019 Garden Grove Blvd., Ste.#204
Garden Grove , CA 92843
chesterthatcher@yahoo.com



# ឥឡូវនេះអ្នកអាចញញឹមបានហើយ!








## ពេទ្យថែរក្សាធ្មេញប្រចាំគ្រួសារ

## FAMILY DENTAL CARE
AT
## SMILE CARE CENTER
626 Snyder Avenue. Philadelphia, Pa 19148

យើងខ្ញុំអាចបកប្រែភាសាខ្មែរជូនលោកអ្នក សូមទាក់ទងជាមួយឈ្មោះ រីន ហេង និងជា លៃនតាវ ដើម្បីណាត់ពិនិត្យ

**WE SPEAK CAMBODIAN. PLEASE CONTACT :**
**MALY CHHORN & CHEALEN TAV 215-391-4100**

**Children and Adults Welcome**

- Exams
- Root Canals
- Extractions
- Cleanings
- Braces
- Dental Implants

**We accept all types of insurance including Medicare & Medicaid**
**PLEASE CALL TO MAKE YOUR APPOINTMENT TODAY !**
**(215) 391-4100**

យើងទទួលយកគ្រប់ប្រភេទ អ៊ិនស្វ៊ីន ដោយរាប់ទាំងម៉េឌីឃែ និងម៉េឌីឃេដ ផង សូមទូរស័ព្ទរកយើងខ្ញុំ នៅថ្ងៃនេះ ដើម្បីណាត់ពិនិត្យនូវលេខ **(215) 391-4100**

Penn Asian Senior Services
# PASSi

**PASSi ជាសមាគមជួយចាស់ជរា និង ជនពិការ**

**សមាគមយើងខ្ញុំមានអ្នកថែរក្សាជាជនជាតិខ្មែរដែលអាចមកថែរក្សាចាស់ជរា និង ជនពិការ**

**សេវាកម្មឥតយកកំរៃផ្តល់ជូនអតិថិជន**

- មកជួបនៅគេហដ្ឋានតាមពេលកំណត់
- ជួយរៀបចំម្ហូបអាហារ និងការបរិភោគ
- ជួយរំលឹកពេលដែលត្រូវពិសារ និងប្រើប្រាស់ថ្នាំ
- ជួយក្នុងពេលងូតទឹក
- ជួយក្នុងការសំអិតសំអាង
- ជួយរៀបចំ និងសំអាតគេហដ្ឋាន
- ជួយបោក និងអ៊ុតសំលៀកបំពាក់
- មានអ្នកកំដរក្នុងការនិយាយលេង
- ជំនួយខាងផ្នែកអនាម័យ
- ជួយទិញម្ហូបអាហារ និងសំលៀកបំពាក់
- ជួយថែរក្សាសមាជិកក្នុងគ្រួសារ
- នៅមានជាច្រើនបន្ថែមទៀត



បើលោក លោកស្រីត្រូវការជំនួយសំរាប់សកម្មភាពរស់នៅប្រចាំថ្ងៃដូចបានរៀបរាប់ខាងលើនេះ សូមទាក់ទងមកលេខទូរស័ព្ទ **215-572-1234** ។
ម្យ៉ាងទៀត បើលោកអ្នកនាងដែលថែទាំមនុស្សចាស់ជរា ជាឪពុកម្តាយ ឬជីដូនជីតា នៅក្នុងបន្ទុក អាចនឹងទទួលប្រាក់បៀវត្សបានទៀតផង ។ សូមអរគុណ !

# DRANOFF ASSOCIATES
*Attorneys at Law*



"ដ្រាណុហ្វ អាសូស៊ីយេត (DRANOFF ASSOCIATE ) គឺជាមណ្ឌលការពារតាមផ្លូវច្បាប់ ដែលធ្វើការប្រកបដោយភក្តីភាព ដើម្បីតំណាងឱ្យអ្នករងគ្រោះ ដែលមានរបួសរូបរាងកាយ ។

ស្ទីវិន ដ្រាណុហ្វ (STEVEN DRANOFF) គឺជាមេធាវីនៅសាលាក្តីមានបទពិសោធន៍យ៉ាងខ្ពស់ខាងសេវាច្បាប់ ៣៥ឆ្នាំ ។

យើងធ្វើការដោយយកកំរៃពីការងារដែលប្រគល់ឱ្យ លោកអ្នកមិនចាំបាច់ចេញថ្លៃចំណាយអ្វីមុននឹងលោកអ្នកទទួលប្រាក់សងពីមុខរបួសលោកអ្នកនោះទេ ។

ជំនួយខាងផ្លូវច្បាប់អាចផ្តល់ជូនជាភាសា ស្ប៉ានីស ខ្មែរ វៀតណាម កូរ៉េ និង ចិន ។

- **របួសលើរាងកាយ :** គ្រោះថ្នាក់រថយន្ត, ឡានឈ្នួល "សិបតា", ឡានត្រឹក, តាក់ស៊ី, ជិះកង់, ថ្មើរជើង, រអិលដួលលើទឹកកក, លើចិញ្ចើមថ្នល់ ឬក្នុងអាគារលក់ទំនិញ, គ្រោះថ្នាក់ដោយបានទិញរបស់ខូចមកប្រើ ឬក៏ឆ្កែខាំ... ។
- **ការប្រហែសក្នុងវិជ្ជាជីវៈ និងសិទ្ធិរបស់អតិថិជន :** ព្យាបាលតាមវិជ្ជាពេទ្យពុំបានត្រឹមត្រូវ, មរណភាពឥតសមហេតុផល, វាយមាយក្នុងការថែទាំមនុស្ស... ។

**DRANOFF ASSOCIATES**
121 South Broad Street, Suit 1210, Philadelphia, PA 19107
215-732-3333 (phone) 215-732-8059 (fax)
sdranoff@dranofflaw.com

# HONG KONG
## Super Market

FAMER´S
BEST

Newly Renovated. Added new section .
Clean and Improved management !
ទើបនឹងកែលំអរថ្មីឡើងវិញ
-បន្ថែមផ្នែកលក់ថ្មីទៀត ហាងស្អាត ហើយបង្កើនគុណភាពគ្រប់គ្រង
**Weekly Sale** លក់ចុះថ្លៃរៀងរាល់សប្តាហ៍

**HONG KONG**
**SUPERMARKET**
**(PA) WEEKLY**
**PROMOTION ITEMS**

**ON SALE PERIOD 8/13/10-8/19/10**




**571 ADAMS AVE.PHILADELPHIA, PA 19120**
**Tel : 215-7281300 Fax : 215-728-1600**




**OPEN**
**7DAY**
8:00-9:00

- ចំណាយ **$140** ដុល្លារ ទទួលបានអង្ករស្រូវស **25** ផោន
- ចំណាយ **$100** ដុល្លារ ទទួលបាននូវភេសជ្ជៈ ឬមីកញ្ចប់មួយប្រអប់ ( តម្លៃ **8.99** )
- ចំណាយ **$25** ដុល្លារ ទទួលបានទឹកសណ្តែកមួយដប ឬទឹកត្រីមួយដប ។

តមកទំព័រទី០១ **វត្តនៅខាងត្បូងហ្វីឡាបានប្រារព្ធពិធីសម្ពោធ...**





នៅលេខក្រោយ យើងនឹងធ្វើអត្ថា- ធិប្បាយអំពីប្រវត្តិ និងការគ្រប់គ្រង វត្តបន្តទៅទៀត ។


មានជំនាញខាងទិញ.លក់ផ្ទះ.ពាណិជ្ជកម្ម. វិនិយោគ ហិរញ្ញវត្ថុ ឬជួល
ផ្តល់ប្រឹក្សាដល់លោកអ្នកដែលផ្តើមវិនិយោគ

Vinh Ho, 215-391-9516

Email: vho.realestate@consultant.com



ANCHOR Real Estate Development
320 Oregon Ave, #3B, Philadelphia, PA 19148

Specialize - Buy_Sell_Invest_Finance_Rent ...
Beginner-investors are welcomed!



# ឱសថស្ថាន ថាំងទី២

TANG PHARMACY II

HYUN TANG, PHARM. D.

FREE DELIVERY Locally

ថាំងឱសថស្ថាន សូមស្វាគមន៍

| ថាំង ទទួលវេជ្ជបញ្ជា បន្តតម្លៃប័ណ្ណ ចំពោះថ្នាំ (Generic Drug) | តម្លៃ $6.00 ចំពោះថ្នាំសំរាប់ ប្រើចំនួន ៣០ ថ្ងៃ | យើងមានថ្នាំចំនួន 500 មុខ ដែលមានគុណភាព ប្រសើរ ដូចថ្នាំមាន ឈ្មោះល្បី (Generic Drugs) |
|---|---|---|

ឱសថស្ថានយើងមានទទួលយក Medicare, Medicaid និងInsurance គ្រោះថ្នាក់ចរាចរ និងគ្រោះថ្នាក់នៅកន្លែងធ្វើការនានា ។ លោកប្រុស និងអ្នកស្រី អាចទាក់ទងជាភាសាខ្មែរ ដោយកញ្ញា គីម ជូលី ( បន្ទាប់ពីម៉ោង ១រសៀល) នៅឱសថស្ថានថាំង ទី២ សូមទាក់ទងហាងថ្នាំយើងខ្ញុំនៅអាស័យដ្ឋាន និងទូរស័ព្ទខាងក្រោម បើលោកអ្នកនៅមានចម្ងល់អ្វីមួយ ។



JULIE KIM, MANAGER
Contact After 1 p.m



Open: mon- Fri. 9a.m- 6p.m
Sat. 9 a.m - 3 p.m

5600 North. 5th Street. Philadelphia, PA 19120 Tel: (215) 224-3333 Fax: (215) 224-3363



# Liberty Real Estate Associates, LLC

Many years experience in Real Estate deals and investment.
One Stop Shop. Buy-Sell-Manage.
Current Listings:

- 7 Laundromats, 5 restaurants, 2 Vegetable stores
- 11 Properties in Chinatown
- 2 Beer Distributors, one liquor license
- 2 Big Shopping Malls, 3 Stripe Malls
- 99 Cents or up Store, Dry Cleaners, Gas Station, Take Out Restaurant
- Residential Homes in good school district
- Pizza Stores, gift store, small supermarket

Our Agents speak English, Chinese, and Vietnamese

មានបទពិសោធន៍ច្រើនឆ្នាំក្នុងការទិញ លក់ និងវិនិយោគអចលនវត្ថុនៅកន្លែងតែមួយមាន: គ្រប់គ្រងផ្ទះ-លក់-ទិញ នៅបញ្ជីរបស់យើងមាន :

- កន្លែងម៉ាស៊ីនបោកខោអាវ ៧-ភោជនីយដ្ឋាន ៥-ហាងបន្លែ២
- ម្ចាស់ផ្ទះ១១កន្លែងនៅឆាយណាថោន
- លក់រាយស្រាបៀ ២-អាជ្ញាប័ណ្ណលក់សុរា
- ផ្សារពាណិជ្ជកម្មខ្នាតធំ ២-ប្រជុំផ្សារតូច១៣
- ហាង៩៩សេន -បោកគក់ស្ងួត ហាងសាំង - អាហារដ្ឋាន
- គេហដ្ឋាននៅជិតសាលារៀនល្អ
- ហាង"ពិតហ្សា"ហាងលក់វត្ថុអនុស្សាវរីយ៍-ផ្សារតូច១

"ភ្នាក់ងារយើងនិយាយភាសាអង់គ្លេស ចិន និងវៀតណាម

| | | | |
|---|---|---|---|
| Richard Li | 267-767-7612 | Luan To | 267-973-0267 |
| Vince Yip | 267-808-1878 | Hala | 609-458-7683 |
| Ron Tran | 484-636-8395 | David App | 215-828-1410 |
| Danny Lin | 215-301-7982 | Kevin Wong | 856-829-0519 |

924 Arch St. 1st Fl. Philadelphia, PA 19107
Tel : 215-625-4725; 625-726, 472 Fax: 215-625-4728



# ហាងជួសជុលឡាន អិន ខេ

NK AUTO

Free Estimate

5901 OXFORD AVENUE. PHILADELPHIA, PA 19149
TEL. 215-533-0163

ជួសជុលទូទៅនឹងសេវាកង់
បើមកធ្វើឡានតាមរយៈពាណិជ្ជកម្មនេះ នឹងទទួលបានបញ្ចុះតម្លៃពិសេស

General Repair & Tire Services
Mention this AD you will receive discount:





Inspection $35.00 Oil Change $20.00

Contact Vannak or Vanney 215-533-0163

# NEW GOLDEN PALACE

**SEAFOOD RESTAURANT**
**801-21 Washington Avenue.**
**Philadelphia, Pa 19147**

**Tel: 215-627-2822**

Business Hours: Monday–Sunday. 10 a.m.–10 p.m.

## សូមអញ្ជើញគ្រោងពិធីរបស់លោកអ្នកជាមួយនឹងយើងខ្ញុំ

*Plan your next event here!*

- *Wedding Reception* • ពិធីមង្គលការ
- *Birthday Parties* • បុណ្យខួបកំណើត
- *Business Meetings* • ប្រជុំការងារជំនួញ
- *Private Parties* • ពិធីជប់លៀងជាឯកជន
- *Fundraisers* • បុណ្យរៃអង្គាសប្រាក់
- *We Accept Reservation for Holidays* • យើងទទួលឱ្យកក់កន្លែងធ្វើពិធីនៅថ្ងៃឈប់បុណ្យទានបាន

## យើងបំរើម្ហូប ឌិម ស៊ុម រាល់ថ្ងៃ ពីព្រឹកដល់ល្ងាច



**We Serve Dim Sum Daily All Day Long &**



**Also Try Our Vietnamese Phở**

កុំភ្លេច ភ្លក់ "ហ្វើ" វៀតណាមរបស់យើង

**From 10 a.m. – 10 p.m.**

## ពិធីជប់លៀងល្ងាចពិសេស ជាមួយក្រុមគ្រួសារ

## ROYAL FAMILY DINNER PACKAGE

សំរាប់៦នាក់-ម្ហូប៧មុខ- **$78**
**DINNER FOR 6 - 7 Entrées $78**



1. Vietnamese Spring Roll
2. Sweet Sour Pork Chops
3. Seafood Bean Curd Soup
4. Lobster with Ginger & Scallion
5. Steam Fish
6. House Special Fried Rice
7. Seasonal Fruit

សំរាប់៨នាក់-ម្ហូប៨មុខ- **$98**
**DINNER 8 – 8 Entrées $98**

1. Palace Appetizer
2. Shrimp Hot & Sour Soup
3. Baby Claims with Black Bean Sauce
4. Sautéed seafood with Chinese Vegetables
5. Lobster with Ginger & Scallion
6. Steam Fish
7. House Special Lo Mein
8. Seasonal Fruit

សំរាប់១០នាក់-ម្ហូប៩មុខ- **$128**
**DINNER 10 – 9 Entrées $128**

1. Fried Shrimp Rolls
2. Salt Baked Shrimp
3. Seafood with Sweet Corn Soup
4. Seafood Bird's Nest
5. Crispy Fried Chicken
6. Double Lobsters with Ginger Scallion
7. Steam/Fried Fish Tilapia
8. House Special Fried Rice
9. Seasonal Fruit

# COMPUTER+ LLC

*SURVEILLANCE SYSTEM, COMPUTER RETAILER, REPAIR & SERVICES*

ជំនាញការខាងជួសជុលកុំព្យូទ័រ លក់គ្រឿងកុំព្យូទ័រ
និងដាក់គ្រឿងថតវីដេអូសំរាប់ការពារសន្តិសុខ

REMOTE VIEWING
Remote Monitoring, Recording, Controlling through Internet from *anywhere* at *anytime*




**5709 N. 5th St., Phila, PA 19120** Open: *Mon-Sat; 10am—6:00pm*
*Peter Hong Ching* * Tel: (215) 276-7000 * Fax: (215) 276-7001
**E-mail:** peterchng_99@yahoo.com www.computerplusllc.com

# Nationwide

Insurance & Financial Service

## សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ

We offer Cheap Price for Every Client

## យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃទាប

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញលោកអ្នក |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រងសុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase Home & Auto Insurance
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ ធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8 Philadelphia, PA 19147
Tel: (215) 463-1257 , Fax: (215) 463-2036




**ដោយ : គីម ភឿន** ***(តពីលេខមុន)***

•••នៅតែ១៥ថ្ងៃទៀតទេដែលវិរៈត្រូវហែផ្កាស្លាពីសមរភូមិទៅកាន់ភ្នំពេញដើម្បីបញ្ចប់ជីវិតឯកោរបស់ខ្លួន ទៅកាន់សុភមង្គលនៃជីវិតមានគូគ្រងមានភាពកក់ក្តៅដែលខ្លួនគេមិនដែលមានសោះក្នុងជីវិតនេះ។ រស់តែក្នុងភាពជាកូនកំព្រាតាំងពីកុមារភាពមកតែជាមួយលោកគ្រូមេកុដិខាងត្បូងព្រះវិហារវត្តលង្ការតាំងតែពីព្រះអង្គនៅក្មេងរហូតដល់ព្រះអង្គក្លាយជាលោកតាក្នុងជរាភាពទៅហើយ លោកតាដ៏ពោរពេញដោយក្តីអាណិត ស្រឡាញ់នឹងប្តូរប្តាច់តស៊ូចញ្ចឹមឱ្យគេបានរៀនសូត្រដល់កម្រិតឧត្តមសិក្សា។ ការខំប្រឹងប្រែងរបស់ព្រះអង្គជាការងារមួយមិនគួរឱ្យជឿបាន។

វិរៈមិនសូវចាំច្បាស់ទេពីជីវិតរបស់ខ្លួនកាលពីកុមារភាព លោកតាបានប្រាប់ថា ឪពុកគេបានពូជាជីវិតនៅក្នុងសមរភូមិជាអ្នកស្នេហាជាតិក្នុងជួរកងទ័ពឥស្សរៈទាមទារឯករាជពីបារាំងតែត្រូវកងទ័ពឥស្សរៈមួយក្រុមទៀតមានទំនោរទៅខាងក្រុមយួនយៀកមិញសម្លាប់។ ម្តាយគេមិនយូរប៉ុន្មានក៏បានចាកលោកនេះទៅដោយសារកណ្តោចកណ្តែងម្នាក់ឯងចិញ្ចឹមកូនកំព្រាឪពុក។ លោកតាបានបិណ្ឌបាតរូបគេយកមកចិញ្ចឹមបីបាច់ឱ្យរៀនសូត្រព្រោះព្រះអង្គត្រូវជាគ្រូឪពុករបស់គេកាលនៅក្មេង។ អ្វីៗក៏ហាក់ដូចផ្សែងអ័ព្ទនៅក្នុងអារម្មណ៍របស់គេគេមិនទាំងចាំមិនច្បាស់មុខមាត់ឪពុកម្តាយរបស់គេយ៉ាងណានោះផង តែគេនៅចាំច្បាស់ពីភាពកក់ក្តៅពេលបាននៅក្នុងរង្វង់ដៃទាំងពីររបស់ម្តាយគេ។ ទោះបីនៅក្រោមម្លប់ព្រះសង្ឃដែលពោរពេញដោយមេត្តាករុណាក៏ដោយ ក៏ភាពស្រេកឃ្លាន បានរស់ក្នុងរង្វង់ដៃទាំងគូរបស់ម្តាយក៏នៅតែចាំបាច់បំផុត។ តែដោយវាសនាបានចាត់ចែងយ៉ាងនេះទៅហើយ ប្រកែកក៏មិនបាន ឥឡូវបានមកជួបនឹងសំណាងថ្មីនេះទៀតគឺបានក្លាយខ្លួនជាប្រសាររបស់គ្រួសារអ្នកមានទ្រព្យស្តុកស្តម្ភនឹងបុណ្យសាក្តិយ៉ាងឧត្តមក្នុងសង្គមខ្មែរ។ មិនតែប៉ុណ្ណោះបានក្លាយខ្លួនជាកូនធម៌នៃគ្រួសារដែលមានសម្បត្តិជាងគេនៅស្រុកតាំងគោកទៀត ការឈានជើងទៅកាន់អាពាហ៍ពិពាហ៍នេះបានស្រស់រលូនគ្មានការលំបាកអ្វីសោះឡើយ។ គេគ្រាន់តែប្រុងប្រៀបខ្លួនចាំតែទៅរៀបការប៉ុណ្ណោះ ឪពុកម្តាយធម៌របស់គេគិតគួរឱ្យគេយ៉ាងម៉ត់ចត់បំផុតនេះក៏ជាភ័ព្វសំណាងដែលគេបានទទួលដោយបុណ្យកុសលអ្វីពីជាតិមុន ឬមកអំពើកុសលគេបានសាងក្នុងជាតិនេះ? គេកាន់តែមានជំនឿទៅលើអំពើល្អដែលគេបានធ្វើហើយគេរឹតតែខំធ្វើតទៅទៀតប្រាថ្នាជាតិណាៗកុំឱ្យអភ័ព្វបែកម្តាយឆ្ងាយឪពុកដូចជាតិនេះ។

បន្តិចទៀតនេះគេនឹងបានរស់ជិតនារីម្នាក់ដែលបានបាក់ចិត្តស្រឡាញ់គេដោយស្មោះនឹងខ្ពង់ខ្ពស់បំផុតក្នុងលោកគេនឹងខំថ្នាក់ថ្នមនាងឱ្យអស់ពីដួងចិត្តស្មោះរបស់គេដែរឱ្យសមនឹងការតស៊ូស្វិតស្វាញនឹងភាពលះបង់ខ្ពស់បំផុតរបស់នាង។ គេនឹងហ៊ានលះបង់អ្វីៗទាំងអស់ដើម្បីនាងព្រោះនាងជានារីដ៏ល្អបំផុតដែលទេវតាបានប្រទានឱ្យគេ ឱ្យគេតែម្នាក់ឯងគត់។ មិនស្មានថាជីវិតអភ័ព្វដូចគេនៅមានថ្ងៃមួយទទួលបានសំណាងព្រេងវាសនាដ៏អស្ចារ្យយ៉ាងនេះ គេដឹងគុណដល់ទឹកដោះម្តាយថ្លៃដែលគេតែងតែបួងសួងសុំឱ្យព្រលឹងម្តាយតាមការពារថែរក្សាសុំឱ្យព្រលឹងឪពុកកុំបោះបង់ចោលគេ តាមផ្តល់កម្លាំងទឹកចិត្តហានក្លាឱ្យគេ ដើម្បីគេពុះពារឧបសគ្គដែលរាំងរាដំណើរជីវិតរបស់គេ។ គេក៏មិនភ្លេចឱនលំទោនចិត្តពីចម្ងាយថ្វាយបង្គំលោកតាដ៏មានវ័យជរា ដោយសារព្រះអង្គនេះហើយទើបគេបានទទួលនូវព្រេងវាសនាបច្ចុប្បន្ននេះ។

វិរៈរំជួលចិត្តយ៉ាងខ្លាំងពេលគេនឹកដល់ខ្សែភាពយន្តនៃជីវិតរបស់គេមិនដឹងថា តើគេអាចស្វែងរកសុភមង្គលជូនដល់គូស្នេហ៍របស់គេបានឬទេ គេនឹកអាណិតដល់នាង មិនគួរឱ្យនាងបាក់ចិត្តមកស្រឡាញ់គេយ៉ាងនេះសោះ ហើយមិនគួរគេបណ្តោយឱ្យចិត្តរបស់គេចងភ្ជាប់នាងធ្វើឱ្យនាងបាក់លោងក្រោកមិនរួច បែរទៅណាពុំកើតដូច្នេះសោះ ហើយខ្លួនគេក៏មិនអាចដកខ្លួនកើតទៀត បើស្លាប់ខ្លួនប្រសើរជាងចាកចេញពីនាង។ បើយ៉ាងនេះទៅហើយត្រូវតែបោះជំហានទៅមុខ ទោះបីស្លាប់រស់ជាមួយគ្នា ហើយគេតាំងខ្លួនជាអ្នកយកជីវិតការពារជីវិតនាងលុះដល់ថ្ងៃអវសាន្ត។

ថ្ងៃអាពាហ៍ពិពាហ៍មង្គលចូលមកកាន់តែជិតសង្គ្រាមកាន់តែពុះកញ្ជ្រោលកាន់តែខ្លាំងឡើង ផ្លូវជាតិពីភ្នំពេញមកតាំងគោក ត្រូវពួកខ្មែរក្រហម និងយៀកកុង កាត់ផ្តាច់ដោយអន្លើ ការធ្វើដំណើរទៅមកពុំអាចប្រព្រឹតទៅបានដោយងាយស្រួលឡើយ។ តែសម្រាប់កូនកម្លោះ និងម្តាយឪពុកកូនកម្លោះ ព្រមទាំងភ្ញៀវសំខាន់ៗម្នាក់ពីរទៀត គ្មានបញ្ហាអ្វីទេ ឧទ្ធម្ភាគចក្រនឹងមកពីភ្នំពេញដឹកជញ្ជូនយកទៅប្រារព្ធពិធីមង្គលការនេះដោយសុវត្ថិភាព នេះជាពាក្យសន្យាយ៉ាងដាច់ណាត់របស់លោកឧត្តមសេនីយ៍ អ៊ុំ សាវុឌ្ឍ ជាបងធម៌របស់កូនកម្លោះ។

កំពុងតែគិតពីរឿងមួយដល់រឿងមួយទៀតមិនចប់មិនហើយ ស្រាប់តែលេចរូបកម្លោះម្នាក់ដើរតម្រង់ មករកវិរៈ ដោយមានទាហានម្នាក់ជូនដំណើរមកផង។ កម្លោះក៏រអាក់រអួលសម្លឹងចំមុខវិរៈ គេស្រឡាំងកាំង ក៏ពោលឡើង "ច្រក! ប្អូនច្រក..."។ កម្លោះច្រកទន់ជង្គង់លុតជង្គង់ចុះមុខវិរៈ ទឹកភ្នែកហូរច្រោក ហុចរបស់ដែលកាន់នៅដៃទៅវិរៈដោយឧទានថា "បងកល្យាណបុប្ផាស្លាប់ហើយ!"។

**(សូមរង់ចាំអានបន្តនៅលេខក្រោយទៀត)**

New World Travel II
ញូវវើលត្រាវែលធូ
Specialized in Selling Flight Tickets
For National and International
ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ
យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថេ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបានទិញសំបុត្រជិះនាវាសមុទ្រ សណ្ឋាគារ ឬ ជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។
Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

ANGKOR AUTO SERVICE, INC.
ហាងជួសជុលរថយន្ត "អង្គរ"
4835 N. 16th Street. Tel : (215) 455-7810
Philadelphia, Pa 19141 Ricky : (215) 485-1425
Specializing in Body Kit and Custom Paint
ជំនាញខាងជួសជុលតួរថយន្ត
និងបាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ
RICKY
Hand Ph.: Ricky 215-485-1425
មុនពេលជួសជុល

ក្រោយពេលជួសជុល

មានបទពិសោធន៍២០ ឆ្នាំ
ជាជាងរថយន្តមានសញ្ញាប័ត្រ
វាយតម្លៃការងារដោយឥតយកថ្លៃ
ហើយយើងជួយសន្សំប្រាក់តម្លៃ
បន្ថយរបស់អ៊ីនស៊ូរិន បានផង
យើងផ្តល់សេវាគ្រប់យ៉ាង :
-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C

បើកពីម៉ោង ៩ ព្រឹក
ដល់ម៉ោង៥ល្ងាច ពីថ្ងៃ
ច័ន្ទ ដល់ ថ្ងៃ សៅរ៍
ចុះតម្លៃជូន 10 % បើបង្ហាញប័ណ្ណពាណិជ្ជកម្មនេះ

ឆ្លើយតបសំនួរមិត្តអ្នកអាន



# Three Cups of Tea

# ទឹកតែ៣ពែង (តពីលេខមុន)

ដោយ : តឹមភៀន

សរសេរតាមលំនាំរឿងពិត

•••ឪពុកម្ដាយរបស់គេជាប់បំពេញការងារនៅប្រទេសតាំងស្សានីយ៉ា គ្រែកនឹងប្អូន១របស់គេពុំបានស្គាល់ស្រុកកំណើតរបស់ខ្លួនច្បាស់លាស់ទេ ពួកគេបានស្គាល់ស្រុកខ្លួនឯងម្ដងម្កាល ដោយសារតែឪពុកម្ដាយគេបានឈប់សម្រាកមកលេងស្រុកក្នុងរយៈពេលខ្លី ឬដោយសារសំបុត្រឆ្លងឆ្លើយសួរសុខទុក្ខសាច់ញាតិតែប៉ុណ្ណោះ។ ពេលត្រឡប់មកនៅស្រុកវិញ គ្រែកបានចូលរៀននៅវិទ្យាល័យទៅហើយ គេឃើញកូនសិស្សអាមេរិកាំងស្បែកខ្មៅជាច្រើនរៀននៅទីនេះ គេមានអារម្មណ៍ថា ស្រុកគេមិនឆ្ងាយប៉ុន្មានពីស្រុកអាហ្វ្រិកតាំងស្សានីយ៉ាឡើយ ព្រោះគេធំឡើងធ្លាប់រស់នៅតែក្នុងបរិយាកាសនៃជនជាតិស្បែកខ្មៅតែយ៉ាងនេះ។ មិនយូរប៉ុន្មានក៏ល្បីពេញសាលាថា មានក្មេងស្បែកសម្នាក់រាងធំខ្ពស់មកពីអាហ្វ្រិកចេះភាសាស្វាហ៊ីលីយ៉ាងស្ទាត់ជំនាញ ធ្វើឱ្យសិស្សខាងកីឡាបាល់ទាត់ម្នាក់មកជួបគេ ហើយក៏ញញឹមចំអកព្រមទាំងបានច្រានគេផ្ទប់ទៅនឹងម៉ាស៊ីនទឹកក្នុងសាលាដោយនិយាយថា "ឯងមិនមែនជាជនជាតិអាហ្វ្រិកាំងទេ"។ រួចហើយក៏បណ្ដោយទុកឱ្យមិត្តភ័ក្តិគេវាយគ្រែក ក្មេងប្រុសស្បែកសចេះភាសាស្វាហ៊ីលីដោយឥតហេតុផលអ្វីទាំងអស់ដូច្នោះទៅ!។

ទោះបីមានរឿងអាក្រក់ពីដំបូងយ៉ាងនេះក្ដី គ្រែកខំអត់ធ្មត់ ហើយខំប្រឹងសិក្សាបានពិន្ទុល្អគ្រប់មុខវិជ្ជា គេក៏មានមិត្តភ័ក្តិរាប់អានច្រើន ហើយមានឈ្មោះល្បីដូចអ្នកចាំទាត់បាល់បញ្ចូលទីយ៉ាងពូកែយ៉ាងនោះដែរ។ តែទោះជាកូនសិស្សពូកែក៏ដោយ គ្រែកមានទម្លាប់អាក្រក់មួយមិនអាចកែបានឡើយ នោះគឺទម្លាប់ "ម៉ោងអាហ្វ្រិកាំង" ។ តាំងពីកុមារភាពម្លេះគ្រែកតែងតែធ្វើការអ្វីយឺតយ៉ាវ មិនទាន់ពេលវេលា។ ម្ដាយគេតែងនិយាយថាគ្រែកប្រើ "ម៉ោងអាហ្វ្រិកាំង"។ គេមិនអាចសម្របខ្លួនតាមរបៀបអាមេរិកាំងបានទេ ក្នុងការចាត់ចែងការងារឱ្យមានបន្ទាត់បទដ្ឋានទាន់ពេលទាន់វេលានោះ។

គ្រួសារគ្រែកម៉កតឹនសុន គ្មានធនធានគ្រប់គ្រាន់ដើម្បីបញ្ជូនឱ្យគ្រែកចូលរៀននៅមហាវិទ្យាល័យបានទេ ក៏គ្រោងនឹងឱ្យគេចូលបំរើកងទ័ព២ឆ្នាំ ក្រោយមករដ្ឋាភិបាលនឹងឧបត្ថម្ភឱ្យចូលរៀនមហាវិទ្យាល័យតាមបំណងរបស់ខ្លួន។ ហេតុនេះហើយបានជាគ្រែកបានចូលទៅក្នុងជួរកងទ័ពហ្វឹកហាត់ជាគិលានុបដ្ឋាកយោធាភ្លាមក្រោយពីប្រឡងចេញពីវិទ្យាល័យបានតែ៤ថ្ងៃគត់។ ចប់វគ្គហ្វឹកហាត់ភ្លាមគ្រែកក៏បានបញ្ជូនឱ្យទៅបំរើកងទ័ពអាមេរិកាំងប្រចាំនៅប្រទេសអាល្លឺម៉ង់។ នៅទីនេះគេមានសំណាងបានដើរទស្សនាចរជុំវិញទ្វីបអឺរ៉ុប ឆ្លងកាត់ធានីធំៗដូចជា ក្រុងរ៉ូមឡុង អាមស្ទើដាម... ។

បំពេញតួនាទីក្នុងកងទ័ពចប់ភ្លាមគ្រែកបានជ្រើសរើសយកមហាវិទ្យាល័យ Concordia College, នៅ Minnesota ដើម្បីបន្តជីវិតជានិស្សិតរបស់ខ្លួន។ នៅទីនេះគេបានចូលរួមក្នុងក្រុមបាល់ទាត់ផង។ ក្រោយពីសិក្សានៅទីនេះបានពីរឆ្នាំគេក៏ប្ដូរទៅសិក្សានៅសាកលវិទ្យាល័យមួយធំទូលាយជាងគឺ University of South Dakota ។ ដើម្បីទ្រទ្រង់ជីវិតនិស្សិតរបស់ខ្លួនគ្រែកបានសុំបំរើក្នុងអាហារដ្ឋានមួយក្នុងមុខងារជាអ្នកលាងចាន ហើយសុំការងារបន្ថែមមួយទៀត ជាអ្នករក្សារបៀបសណ្ដាប់ធ្នាប់ក្នុងមន្ទីរពេទ្យ។ គ្រែកមានលុយគ្រប់គ្រាន់ចាយវាយខ្លួនឯងរួចហើយនៅអាចផ្ញើទៅជូនឪពុកម្ដាយមួយចំនួនទៀតរៀងរាល់ខែ។ ក្នុងពេលដែលគ្រែកកំពុងតែសិក្សាគីមីវិទ្យានិងគិលានុបដ្ឋាកនោះ ឪពុកគេមានជំងឺដ៏ធ្ងន់មួយមកបៀតបៀន គឺជំងឺមហារីក។ គ្រែកចង់ផ្អាកការសិក្សាមួយរយៈមកថែជំងឺឪពុក តែលោក Damsey Mortenson ជាឪពុកមិនព្រម ដោយហាមឃាត់កូនកុំឱ្យមានគំនិតបោះបង់ការសិក្សាឱ្យសោះ ហេតុនេះហើយគ្រែកត្រូវចំណាយ៦ម៉ោងបើកបរមកផ្ទះរៀងរាល់ចុងអាទិត្យ ដើម្បីមកមើលថែឪពុកនៅមីនីសូតា។ នៅឆ្នាំ១៩៨១ ឪពុករបស់គ្រែកបានលាចាកលោកនេះក្នុងពេលដែលគេទើបមានអាយុ២១ឆ្នាំប៉ុណ្ណោះ។ ពេលឪពុកបានស្លាប់ទៅហើយ គេក៏ចាប់ផ្ដើមព្រួយបារម្ភថា នឹងបាត់បង់ប្អូនស្រីគេឈ្មោះគ្រីស្ទីន នោះមួយទៀត ព្រោះពេលនេះការប្រកាច់បណ្ដាលមកពីជំងឺឆ្កួតជ្រូករបស់នាងកាន់តែធ្ងន់ធ្ងរឡើងៗ ។ ហេតុនោះហើយពេលគេប្រឡងចេញពីមហាវិទ្យាល័យជំនាញខាងគីមីវិទ្យា និងគិលានុបដ្ឋាកភ្លាម គេក៏វិលត្រឡប់មកផ្ទះរស់នៅជាមួយម្ដាយ និងមើលថែប្អូនស្រីរបស់គេ។ គេជួយរកការងារឱ្យប្អូនធ្វើក្នុងរោងចក្របាន ហើយក៏នាំប្អូនជិះឡានក្រុងឱ្យចេះដឹង និងស្គាល់កន្លុកកន្លៀតសព្វគ្រប់ សមល្មមថានឹងអាចទៅធ្វើការ និងត្រឡប់មកផ្ទះដោយខ្លួនឯងបានហើយទើបគេបណ្ដោយទុកឱ្យប្អូនទៅមកដោយខ្លួនឯង។ គេក៏ណែនាំប្អូនស្រីក្នុងការជ្រើសរើសគូស្រករផងដែរ។ តែតម្រូវការចាំបាច់បំផុតរបស់ប្អូនស្រីគេនោះចេះតែចងចាំជានិច្ចនៅក្នុងអារម្មណ៍របស់គេ នោះក៏ជាការចាំបាច់របស់គេផងដែរ គឺគេចង់សិក្សាពីប្រព័ន្ធសរសៃប្រាសាទដែលចេះតែធ្វើឱ្យប្អូនស្រីគេប្រកាច់នោះ ហើយចង់ចាប់យកអាជីពនោះសម្រាប់ជីវិតអនាគតរបស់គេតែម្ដងទៅ។

(សូមរង់ចាំអាននៅលេខក្រោយជាបន្ត)

From :Philadelphia



# សួស្ដីឆ្នាំថ្មី

# ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

## Rathe`s Auto Service




State and Emission
Inspection General
Repairs and Maintenance

MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY

-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរប្រ៊្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨
ទៅ : -ដូរប្រេងក៏រត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ ពាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្ដាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្ដេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

# Yes you can!

... get free or low-cost health insurance for your children.

- Did you lose your health insurance when you lost your job?
- Do your children have no health insurance?
- Do you wonder how you'll afford your kids' next doctor visit?

AmeriChoice
A UnitedHealth Group Company

(215) 360-9841
Leap Thach

Your children deserve to be healthy.
AmeriChoice can help.






Think of life insurance from New York Life as a gift of financial protection. With cash value that increases every year,* even in times like these, your whole life policy can help fund a college education, pay off debts, or let you plan for the unexpected.† And what's more, it's backed by the highest possible ratings for financial strength.‡ Give your family the most selfless gift of all, a secure financial future.

NEW YORK LIFE

Concerned about your family's future? Talk to your New York Life agent today.

Pom Srey
Agent

**New York Life Insurance Company**
100 Witmer Road Suite 100
Horsham, PA 19044
(215) 441-6280
psrey@ft.newyorklife.com

THE COMPANY YOU KEEP®
www.newyorklife.com

*As premiums are paid. †The cash value in a life insurance policy is accessed through policy loans, which accrue interest at the current rate, and cash withdrawals. Loans and withdrawals will decrease the death benefit and cash value. ‡Standard & Poor's (AAA), A. M. Best (A++), Moody's (Aaa) and Fitch (AAA) for financial strength. Source: Individual Third Party Ratings Reports (as of 6/16/09). © 2009 New York Life Insurance Company, 51 Madison Avenue, New York, NY 10010

100121 AGY-1250 00398624 CV 6/11



Sav-Mor PHARMACY Tel: 215-467-1220

ឱសថស្ថានខ្មែរ

Sav-Mor PHARMAC

Sam EA R.Ph.

2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447



បំរើលោកអ្នកដោយមិត្តភាព និងឆាន់ចិត្ត

▶▶ Sav Mor គឺជាឱសថស្ថានបំរើការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំតាមវេជ្ជបញ្ជា ជាភាសាខ្មែរបាន យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀត ផង យើងមានលក់កាត់សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ និងអន្តរជាតិ

* Accept most insurance plans including Medicare & Medicaid
* Easy Prescription transfer
* Inside. Prepaid phone card. Call Cambodia.



# FOR SALE BY OWNER

HASS´S AUTO ជួសជុលតួឡានដែលបុកគ្នាម្ចាស់ហាងចូលនិវត្តន៍-ហាងមានដំណើរការ១៧ឆ្នាំមកហើយ-ពាណិជ្ជកម្មមានលំនឹងល្អគ្រប់រដូវលោកអ្នកអាចទិញតែពាណិជ្ជកម្មក៏បាន-ទិញដីជាមួយនឹងផ្ទះក៏បាន-ទិញទាំងពីររួមគ្នាក៏បាន បើចង់ដឹងច្បាស់សូមទូរស័ព្ទរកឈ្មោះ "នីក"

Owner is retiring. 17 years in business at this location. Well established business, all seasons are busy. Option to buy only business, real estate, or both.




Contact Nick: 267-242-7938
615 W. Fisher Ave. Phila, Pa 191203



Danny's Café





Foods & Hoagies

1. Beef Stew Serve with Bread
2. Curry Chicken Serve with Bread
3. Curry Beef Saramann Serve with Bread
4. Meatball Soup Serve with Bread
5. Mi Siam

1730 Snyder Ave. Philadelphia, PA 19145 / Mon – Fri: 7am – 7pm Saturday: 9 am – 8 pm / Sunday : CLOSED
Tel: 215.467.4082 Fax: 215.467.4642 / Thank You, Please come again !



# FRANK'S TIRES




2654 S. FAIRHILL ST.
(215) 334-2261
OPE N 7 DAYS A WEEK
8 A.M. – 7 P.M.

NEW & USED TIRES
ESTBLISHED SINCE 1984

តមកពីទំព័រទី ០១

## បុណ្យអុំទូកនៃសហគមន៍អាស៊ីអគ្នេយ៍...

ដែលបានប៉ាន់ស្មានមិនតិចជាង ៨០% ដែលយកចិត្តទុកដាក់ចូលរួមថែរក្សាវប្បធម៌របស់ជាតិខ្លួន ទាំងមិនដឹងច្បាស់ថា វប្បធម៌ ទំនៀមទំលាប់ដូនតាខ្លួនជាអ្វីពិតប្រាកដនៅឡើយក្ដី ។

កាលពីប៉ុន្មានឆ្នាំមុន ឡូវែលនេះធ្លាប់ជាជម្រុកនៃអបាយមុខដ៏សំខាន់មួយ ដែលប្រឆាំងនឹងសន្តិសុខសង្គមប្រឆាំងនឹងច្បាប់ តែប៉ុន្មានឆ្នាំចុងក្រោយនេះក្រុមអ្នកថែរក្សាសន្តិសុខសង្គម មានប៉ូលិស តុលាការបានរឹតបន្តឹងការអនុវត្តន៍ច្បាប់បានច្រើនហើយ ពិធីបុណ្យអុំទូកឆ្នាំនេះ ពុំមានពូភាពប្រទូស្តរ៉ាយ គួរឱ្យភ័យព្រួយអ្វីជាដុំកំភួនទៀតឡើយ ។

ដោយសារបុណ្យអុំទូកជាទំនៀមទំលាប់មួយដែលក្លាយទៅជាវប្បធម៌នៃអាស៊ីអគ្នេយ៍ទៅហើយ គេឃើញអ្នកគ្រប់គ្រងសាសនាច្រើនក្រុមចេញមកបង្ហាញខ្លួន ដែលពេលបុណ្យអុំទូកថ្ងៃនោះ មានព្រះសង្ឃ លាវ ថៃ និងខ្មែរ រៀបរោងខុសៗគ្នា មានអាចារ្យខាងសាសនាគ្រីស្ទ មានទាំងក្រុមសាសនាឈៀងហៃ ក៏មកធ្វើការផ្សព្វផ្សាយគួរឱ្យចាប់អារម្មណ៍ខ្លាំងណាស់ដែរ ។

បុណ្យបានចប់នៅម៉ោង ៥រសៀល កន្លែងតាំងពិពណ៌ កន្លែងលេងភ្លេងរាំកំសាន្ត កន្លែងចតរថយន្តដែលណែនតឹងផ្អឹសនាពេលព្រឹក និងរសៀល ឥឡូវបានត្រូវបន្ធូរស្បើកមកវិញ តែមិនចប់នៅត្រឹមនេះទេ... នៅល្ងាចនេះ ស្ទើរគ្រប់គេហដ្ឋាននៃគ្រួសារសហគមន៍ មានខ្មែរយើងជាដើម គេផ្ដើមជួបជុំ គ្រួសារញាតិមិត្តមកពីទីឆ្ងាយៗ... ដោយខានជួបគ្នាយូរ គេនាំគ្នាទទួលភ្ញៀវ ដុតសាច់ ត្រី មាន់ ឬគោ ពិសារស្រា ឬភេសជ្ជៈយ៉ាងទ្រហឹងអ៊ឹងកងស្ទើរគ្រប់ផ្ទះ ។ ឡូវែល និងតំបន់ជុំវិញ នារាត្រីថ្ងៃបុណ្យអុំទូកនោះជារាត្រីរីករាយមួយទៀត ដែលសហគមន៍ អាស៊ីទាំងអស់ រកឃើញភាពញញឹមរបស់ខ្លួនឡើងវិញ បន្ទាប់ពីបានត្រូវសង្គ្រោះចេញពីក្រញាំពួកឆ្នាំក្រហមគ្រប់ជំនាន់រួចមក ។ "ខ្មែរប៉ុស្តិ៍"





## អ្នកមានទោសខ្មែរនឹងត្រូវនិរទេសថែមទៀត

**ឡូវែល** : ថ្ងៃទី២១ ខែសីហានេះ ក្រុមអ្នកប្រឆាំងនឹងច្បាប់អនុញ្ញាត្តិឱ្យនិរទេសអតីតពិរុទ្ធជនខ្មែរឱ្យត្រឡប់ទៅកម្ពុជាវិញ បានសំដែងប្រតិកម្មច្រើនគ្នាមិនពេញចិត្តឱ្យមានការអនុវត្តន៍ច្បាប់នៅសហរដ្ឋអាមេរិកតទៅទៀតទេ ។



**ប៊ុនសុង ស៊ូ** : និយាយថាច្បាប់នេះអយុត្តិធម៌ព្រោះវាបានបញ្ជូនកូនខ្មែរ១៨៧នាក់ហើយទៅកម្ពុជាវិញ ឥឡូវនេះកូនខ្មែរប្រមាណ៥០នាក់ទៀត កំពុងត្រូវប៉ូលិសឃាត់ខ្លួនបញ្ជូនទៅកម្ពុជាមុនខែធ្នូខាងមុននេះថែមទៀត សុំឱ្យសភាប្ដូរច្បាប់នេះចេញទៅ ! ។

**វាស្នា ពេជ្រ** : (ធ្លាប់មាន ទោស១ឆ្នាំ ដោយចាប់



ចោទថា លក់កញ្ឆា តែទោសនោះបានត្រូវបានលប់ចោលបានដោយការទាមទាររបស់មេធាវីដែលមានបទ ពិសោធន៍) ខ្ញុំបានធ្លាប់ធ្វើការជួយលើកដំកើងសង្គមច្រើន... តែខ្ញុំនៅវ័យក្មេង តែងមានការភ្លាំងភ្លាត់ច្រើនដូចអ្នកដទៃឯទៀតដែរ តែខ្ញុំយល់ថា មិនគួរឱ្យបន្តប្រើច្បាប់របៀបនេះតទៅទៀតទេ ដោយសារពួកយើងមកសហរដ្ឋអាមេរិកនេះស្របច្បាប់ ហើយមានកំហុសដោយសារសង្គមជម្រុញ បើអ្នកណាគេបំពេញទោសគេរួចហើយៗគេកែខ្លួនបានថែមទៀត មិនត្រូវបញ្ជូនគេឱ្យទៅបែកបាក់គ្រួសារអីទៀតទេ ។

**នៅហ្វីឡាដែលហ្វៀ** : សកម្មភាពដូចគ្នានេះក៏បានត្រូវសហគមន៍ខ្មែរ ប្រឹងប្រែងទប់ស្កាត់ច្បាប់និរទេសកូនខ្មែរនេះដែរ ។ កាលពីថ្ងៃទី១២ ខែសីហាកន្លងទៅ



សមាជិកសហគមន៍ បានធ្វើបាតុកម្មនៅវត្តព្រះពុទ្ធវង្សី ជ្រុងផ្លូវលេខ៦ និង រីតន័រ ដើម្បីទាមទារឱ្យដោះលែងឈ្មោះ ហូវ លីគុល និងឱ្យរួចពីការនិរទេសខ្លួន ។

**ជេរិត សេង** : ថ្ងៃទី៦ ខែសីហា ហូវ លីគុល បានត្រូវឃុំខ្លួននៅ (ICE) រង់ចាំការនិរទេសខ្លួន ។ មកដល់សហរដ្ឋអាមេរិក ដោយគេចពីខ្មែរក្រហមនៅពីនៅយុវជនបានជាប់ទោស១២ឆ្នាំគេបានបំពេញទោសគេរួចហើយ ថែមទាំងបានកែខ្លួនជាមនុស្សដ៏ប្រសើរ សម្រាប់ជួយសហគមន៍ខ្លួនកុំឱ្យដើរតាមផ្លូវខុស ហើយអាចមានទោសដូចខ្លួនទៀត ។ ឥឡូវអាយុ៣០ឆ្នាំហើយ គេបានក្លាយទៅជាជន្នលសម្រាប់ពង្រឹងសហគមន៍របស់ខ្លួនបានបែរជាត្រូវសហរដ្ឋអាមេរិកបញ្ជូនត្រឡប់ទៅកម្ពុជាវិញ បណ្ដាលឱ្យបែកបាកគ្រួសារ និងញាតិមិត្តជាថ្មីម្ដងទៀត ។ សហគមន៍ខ្មែរថ្ងៃនេះ ជួបជុំគ្នាដើម្បីចង់ប្ដូរឱ្យប្រព័ន្ធច្បាប់អន្តោប្រវេសន៍មានមនុស្សធម៌ឡើងវិញ ។

**មាណា** : បានប្រកូកឱ្យសាធារណៈជនសរសេរសំបុត្រទៅសមាជិកសភាអាមេរិកាំង អ្នកធ្វើច្បាប់ទាមទារឱ្យប្ដូរច្បាប់អន្តោប្រវេសន៍នេះឱ្យបានគ្រប់ៗគ្នា ៕



ការិយាល័យច្បាប់របស់មេធាវី

អេមេត ម៉ាឌិន

LAW OFFICES OF R. EMMETT MADDEN, ESQUIRE



**ការពារករណីឧក្រិដ្ឋ**

- បញ្ហាធ្វើតាក់
- បញ្ហាជាមួយមន្ត្រីពន្ធដារ
- បើកបរនៅពេលស្រវឹងស្រា ឬគ្រឿងញៀន
- រំលោភរូបរាងកាយ
- ចាប់ខ្លួនដោយលក់ ឬប្រើគ្រឿងញៀន
- ក្លែងបន្លំធានារ៉ាប់រង
- ការដកហូតអាជ្ញាប័ណ្ណ
- ករណីអន្តោប្រវេសន៍

**របួសលើរាងកាយ**

- គ្រោះថ្នាក់រថយន្ត
- ព្យាបាលជម្ងឺមិនត្រឹមត្រូវ
- រអិលដួល
- របួសដោយឆ្កែខាំ
- គ្រោះថ្នាក់ឡានធំ
- គ្រោះថ្នាក់កង់ម៉ូតូ
- គ្រោះថ្នាក់ផ្នែកខួរក្បាល

ពួកយើងមានបុគ្គលិកនិយាយភាសាខ្មែរ

CALL 215-884-9300

www.thephillylawers.com